ឆ្នាំទី ៥

លេខ ១១-១២

# ទស្សនាវដ្ដី សាស្ត្រាចារ្យ

ផ្សាយចេញរាល់ត្រីមាស



ផ្សាយចេញ
ពីសមាគមសាស្ត្រាចារ្យ

ទីចាត់ការបណ្ដោះអាសន្ន
១២៣ E ផ្លូវ...

ភ្នំពេញ

# [illegible]

# [illegible]

[illegible]



ខ.ខ.ជួ ២១-១-៦៨

ក្នុងព្រះរាជពិធីចំរើនព្រះជន្មនេះ

# ស.ស.ខ. សូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយ



## សូមឲ្យសម្តេចឪ

## ព្រះអង្គទ្រង់ប្រកបដោយព្រះជន្មរាប់រយព្រះវស្សា!

សូមអានសេចក្តីថ្វាយព្រះពរ នៅខាងក្នុង

# ស.ស.១. សូមបេដ្ឋាឧបត្ថម្ភទាំងស្រុង

## នូវព្រះរាជនយោបាយសេដ្ឋកិច្ច ហើយនឹង

## ព្រះរាជយោបល់អំពីការកែទំរង់ការសិក្សា !

ឆ្នាំ ១៩៦៣ បានកន្លងផុតទៅ ដោយនាំយកទៅជាមួយនឹងខ្លួនផង នូវគ្រោះអាសន្នធំៗ ជាច្រើន ដែលប្រជាជាតិនិងប្រជាពលរដ្ឋជាទីស្នេហារបស់យើងអាចនឹងត្រូវរងពីសំណាក់មហាអំណាចលោកសេរីមានអាមេរិកជាមេហើយនឹងបរិវារ ហើយនិងពីសំណាក់នាយទុនក្បត់ជាតិមានឈ្មោះ សំ-សារី ជាមេ ដែលស៊ុមគ្រលំឃុបឃិតជាមួយនឹងគ្នា ។ ព្រមជាមួយនេះ ឆ្នាំ ១៩៦៣ ពិសេសគឺចុងឆ្នាំ បានបង្កបង្កើតនូវលក្ខណៈសម្បត្តិងាយស្រួលជាច្រើនប្រការ ដើម្បីឲ្យប្រជាពលរដ្ឋយើងអាចរស់នៅដោយសុខសប្បាយ នៅក្នុងឯករាជ្យខាងសេដ្ឋកិច្ចតទៅទៀត ។

គឺក្នុងចំណុចនេះហើយ ដែលឆ្នាំ ១៩៥៣ បានមកជួបនឹងឆ្នាំ ១៩៦៣ ! តាមពិត ១០ ឆ្នាំបន្ទាប់ពីជោគជ័យខាងនយោបាយមក សម្តេចឪក៏ទ្រង់បានសព្វព្រះរាជហឫទ័យបំពេញព្រះសកម្មប្រយុទ្ធដើម្បីឯករាជ្យខាងសេដ្ឋកិច្ចទៀត ។ ឥឡូវនេះ ដើម្បីនឹងកសាងសុភមង្គលជូនកូនចៅព្រះអង្គ សម្តេចឪទ្រង់បានពុះពារយ៉ាងក្លាហានអង់អាចនូវឧបសគ្គទាំងមួយរយជំពូក ដែលមេក្លោងលោកសេរីហើយនឹងបរិវារទាំងជិតទាំងឆ្ងាយ ព្រមទាំងពួកនាយទុនក្បត់ជាតិ ហើយនឹងពួកមន្ត្រីវៀចវេរ បានបង្កឡើងដើម្បីនឹងជំទាស់ព្រះរាជនយោបាយសេដ្ឋកិច្ចនេះ ។ ប៉ុន្តែ ទោះបីបច្ចាមិត្តពាលខាងលើបានបង្កប់ផែន

ការបំផ្លិចបំផ្លាញរបស់វាច្រើនយ៉ាងណាក៏ដោយ លទ្ធផលក៏ឃើញថាបានប្រសើរគួរជាទីគាប់ចិត្ត៖ ជាតូបនីយកម្មនៃវិស័យទាំងឡាយជាផ្លូវវែកបានធ្វើ " សូណិចសុម ,, ដែលជាបេះដូងក៏មានរូបពងទីងមានសកម្មភាព ជំនួយអាមេរិកទាំងខាងយោធា ទាំងខាងសេដ្ឋកិច្ច បច្ចេកទេស និងវប្បធម៌ ដែលជាអាភៀនជាគ្រឿងពុលក៏បាន " ទាត់ចោល " ការដើរចេញពីប្រទេសយើងនៃគណៈបេសកកម្មរបស់គេ ក៏បានកំណត់កាលបរិច្ឆេទ ហើយចំពោះការសិក្សាវិញ សម្តេចឪក៏ទ្រង់បានណែនាំបំភ្លឺឲ្យកែទំរង់ទៀត ! ការសិក្សាដែលជាវិស័យមួយជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការពង្រីកសេដ្ឋកិច្ច ។

ដូចនេះ មាគ៌ាជាតិ មាគ៌ាដ៏ត្រឹមត្រូវនោះ ព្រះអង្គបានត្រួសត្រាយរួចហើយ ហើយទ្រង់ក៏ថែមទាំងបានចង្អុលបង្ហាញវិធីដើរទៅមុខថែមទៀតផង ។ ប្រសិនជានៅសល់អ្វីមួយនោះ គឺនៅសល់តែយើងដែលជាកូនចៅព្រះអង្គទាំងគ្នាអនុវត្តទៅ អនុវត្តតាមព្រះរាជបញ្ញាឲ្យចំៗ អនុវត្តឲ្យឆាប់ៗ កុំបង្អែរបង្អង់ អនុវត្តឲ្យសកម្ម និងអនុវត្តដោយជំនឿជឿជាក់ គឺជឿទៅលើជោគជ័យជាអវសាននៃការកែទំរង់សេដ្ឋកិច្ចជាតិនេះឯង ។

▣

ក្នុងក្របខ័ណ្ឌនៃការណែនាំកែទំរង់ការសិក្សា សម្តេចឪទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទានសន្និសីទមួយកាលពីថ្ងៃ ១៤ ធ្នូ ដើម្បីនឹងពិនិត្យបញ្ហាថា " តើនវភាពទាំងនេះ ( គឺនវភាពទាំងប៉ុន្មានដែលបានបញ្ចូលទៅក្នុងកម្មវិធីយើងរួចហើយ ) គ្រប់គ្រាន់ហើយឬនៅ បើប្រៀបធៀបមកនឹងវិសាលភាពនៃការកែទំរង់ថ្មីៗ ដែលយើងបានសំរេចហើយនេះ ( គឺការកែទំរង់សេដ្ឋកិច្ច ) " ។

តាមពន្លឺនៃសន្និសីទនេះ សម្តេចព្រះបិតា សាមគ្គីភាពជាតិទ្រង់បានបង្ហាញភស្តុតាងជាថ្មីទៀតថា ព្រះអង្គមិនគ្រាន់តែជាអ្នកនយោបាយដ៏ក្លាហានប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គ

ក៏ទ្រង់ប្រកបពោរពេញដោយលក្ខណៈជាអ្នកគរុកោសល្យទៀតផង អ្នកគរុកោសល្យជំនាន់ថ្មីដែលយល់ថា ការសិក្សាអប់រំត្រូវតែមានគោលបំណងទៅបំរើសេចក្ដីត្រូវការរបស់ប្រទេសជាតិក្នុងសម័យណាមួយដ៏ច្បាស់លាស់ ។ ឯសេចក្ដីត្រូវការរបស់ប្រទេសយើងក្នុងសម័យនេះ គឺការបង្កើតផល គឺការអប់រំយុវជនឲ្យមានទស្សនៈស្នេហាការងារផលិតកម្ម ដើម្បីនឹងសំរេចនូវការកែទំរង់សេដ្ឋកិច្ចដែលជាឯករាជ្យទីពីររបស់យើងនេះឯង ។

ដើម្បីនឹងប្រែប្រួលទស្សនៈយុវជនយើង ពី " ការិយាល័យនិយម " បច្ចុប្បន្នឲ្យទៅស្នេហាស្ម័គ្រនឹងការងារបង្កើតផលវិញ នោះកម្មវិធីសិក្សាមានសារៈសំខាន់មួយប្រកបទៅដោយឥទ្ធិពលធំណាស់ ។ កម្មវិធីសិក្សាយើងដែលរហូតមកទល់នឹងឆ្នាំ ១៩៥៨ គ្រាន់តែជាការចម្លងពីកម្មវិធីបារាំង បានទទួលការកែទំរង់មួយយ៉ាងសំខាន់នៅក្នុងឆ្នាំនោះ ។ ការកែទំរង់នេះសំខាន់ត្រង់បានធ្វើឲ្យកម្មវិធីសិក្សាយើងមានលក្ខណៈស្របមកតាមលក្ខណៈរបស់ជាតិយើង ។ ដូចនេះ កម្មវិធីនៃបឋមសិក្សានិងមធ្យមសិក្សាក៏បានទទួលខេមរូបនីយកម្ម ចំណែកឯកម្មវិធីនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សា និងមធ្យមសិក្សាបត្រភាគទី ១ - ទី ២ ក៏បានកែទំរង់ដែរ ។ ប៉ុន្តែ ការកែទំរង់នេះគ្រាន់តែជាជំហានដំបូងប៉ុណ្ណោះទេ ។ កាលៈទេសៈសព្វថ្ងៃ ដែលប្រទេសកម្ពុជាបានសំរេចនឹងដើរតាមមាគ៌ា " សង្គមនិយម ៦០ % " ទៅហើយ ហើយដែលសម្ដេចព្រះអង្គកំពុងតែលើកឡើងនូវការកែទំរង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុដ៏ក្លៀវក្លានេះ បានដាក់បញ្ហារបបសិក្សាយើងឲ្យនៅក្រោមទិដ្ឋភាពមួយថ្មីស្រឡះ ហើយការកែទំរង់ឆ្នាំ ១៩៥៨ ក៏ប្រែជាមានសភាពចាស់ហួសសម័យទៅវិញ ក្នុងចំណុចជាច្រើន ។

តើកម្មវិធីសិក្សាដែលមានភារៈនឹងគាំទ្រហើយបំរើការកែទំរង់សេដ្ឋកិច្ចរបស់យើងនេះត្រូវមានគោលការណ៍យ៉ាងណាខ្លះ ? - ចម្លើយចំពោះបញ្ហាដ៏ធំទូលំទូលាយនេះ សម្ដេចទ្រង់បានគូសបញ្ជាក់យ៉ាងច្បាស់លាស់ណាស់ហើយថា ៖

"តាមពិត ខ្ញុំយល់ឃើញថា គួរណាស់តែបញ្ចូលទៅក្នុងកម្មវិធីសិក្សាយើងនូវសកម្មភាពសេដ្ឋកិច្ចទាំងឡាយណា ដែលធ្វើឲ្យសិស្សយើងមានទំលាប់ក្នុងការប្រកបមុខរបរទាំងឡាយ ដែលជួយដល់ការពង្រីកសេដ្ឋកិច្ចនៃប្រទេសយើង ។ ធ្វើដូចនេះ គឺយើងបានផ្តល់ដល់សិស្សទាំងនោះ នូវច្រកចេញនានាដែលថ្ងៃក្រោយទៅនឹងមានផលប្រយោជន៍ដល់ប្រទេសជាតិផង ដល់ខ្លួនគេផង ។ ខ្ញុំភប់ជាឧទាហរណ៍ថា សិស្សយើងអាចនឹងធ្វើដំណាំ ចិញ្ចឹមសត្វ ធ្វើរបរផ្សេងៗ ។ល។ ... ហើយសហករណ៍ក៏អាចនឹងបង្កើតឡើងនៅក្នុងសាលារៀនយើងដែរ ដូចជាគេបានធ្វើនៅក្នុងប្រទេសកុម្មុយនីស្តខ្លះអីចឹង ។ ធ្វើដូច្នេះ គឺយើងនឹងបានចំណេញមួយផ្នែកទៀតត្រង់អាចបន្ថយកម្មវិធីសិក្សាយើងអំពីមុខវិជ្ជាខ្លះ ដូចជាប្រវត្តិវិជ្ជា ភូមិវិជ្ជា អក្សរសាស្ត្រនិងសិល្បៈដែលទាក់ទងនៅនឹងប្រទេសដទៃ ..."។

*ក្នុងការបំភ្លឺការកែទំរង់សិក្សាធិការជាតិនេះ សម្តេចឪ ទ្រង់បានណែនាំឲ្យទុកកន្លែងសំខាន់ៗជាងគេបំផុតសំរាប់ការងារប្រតិបត្តិ សំរាប់គណិតវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិជ្ជា ការសិក្សាខាងកសិកម្ម ការពង្រីកសិប្បកម្ម ការពង្រីកគំនិតសហករណ៍ ការអប់រំឲ្យទៅជាផលិតករតូចៗ . . . គោលគឺធ្វើឲ្យការសិក្សាមានលក្ខណៈជាការសិក្សាបង្កើតផល ហើយធ្វើឲ្យសាលារៀនប្រែលក្ខណៈពី "សាលារៀនស្ងួត" ទៅជា "សាលារៀនរស់" ទៅវិញ ។ ចំណែកឯវិជ្ជាឯទៀតៗ ដូចជាភូមិវិជ្ជា ប្រវត្តិវិជ្ជា អក្សរសាស្ត្រ ដែលទាក់ទងទៅនឹងប្រទេសដទៃ ក៏គួរតែបន្ថយដែរ ពីព្រោះ ម្យ៉ាងដើម្បីនឹងទុកពេលយកទៅរៀនវិជ្ជាពោលខាងលើ ហើយម្យ៉ាងទៀត គោលបំណងកាលៈទេសៈក៏មិនបានទាមទារឲ្យយុវជនយើងទៅជាអ្នកជំនាញខាងប្រវត្តិវិជ្ជានៃប្រទេសនេះ ឬប្រទេសនោះក៏ទេដែរ ។ ដែលថាបន្ថយនេះ គឺមិនមែនលុបចោលទាំងស្រុងទេ ពីព្រោះអនាគតបញ្ញាវន្តរបស់យើង បើនឹងធ្លាក់ទៅដូចជា* "អ្នកប្រាជ្ញនៃក្រុងប៉ុបៃ ដែលមិនដែលបានដឹងសោះថា ប្រទេសកម្ពុជាមានអាកាសចរណ៍និងអាកាសយានដ្ឋាន ដែលយន្តហោះម៉ាស៊ីនឡូននិងយន្តហោះធុន 'ហ្សេត Jet' អាចនឹងចុះចតបានដែរ ..." *នោះទៅ ក៏មិនកើតដែរ ។*

*គឺមានតែការសិក្សាអប់រំដែលផ្តោតលើគោលការណ៍ដូចពោលខាងលើនេះទេ ទើបអាចទាញយុវជនយើងឲ្យស្រឡាញ់ការងារបង្កើតផលបាន ព្រោះតាមធម្មតា "តែគេចេះអ្វី គេចង់តែធ្វើនោះ" ហើយ ។*

ម្យ៉ាងទៀត យើងយល់ថាវិជ្ជាទាំងឡាយ ប្រសិនជាបង្រៀនជាភាសាខ្មែរនោះ យុវជនមុខតែអាចនឹងងាយក្រេបជញ្ជក់រសជាតិនៃវិជ្ជាទាំងនោះ ជាងបង្រៀនជាភាសាបរទេស ។ ព្រោះវិជ្ជានិមួយៗ គ្រាន់តែវិជ្ជាខ្លួនឯងនោះក៏ពិបាកស្មុគស្មាញរួចទៅហើយ ដូចនេះ យានភាសាបរទេសជាការពិបាកទីពីរដែលមកស្រោបពីក្រៅវិជ្ជានោះថែមទៀត ។ ហើយតាមធម្មតា យានភាសានេះច្រើនតែបង្កើតជាឧបសគ្គមិនឲ្យសិស្សចូលទៅដល់ខ្លឹមនៃវិជ្ជាទៀតផង ។ ប្រសិនជារៀនជាភាសាជាតិ (យកភាសាខ្មែរជាយានភាសា comme langue véhicule) វិញ នោះសិស្សមុខតែងាយយល់ដោយច្បាស់លាស់ ងាយចាំ ហើយយកពេលនឹងកម្លាំងប្រាជ្ញាទៅរៀនគណិតវិជ្ជា ឬវិទ្យាសាស្ត្រទៅវិញ ។ ឯភាសាបរទេសវិញ ដូចជាបារាំង អង់គ្លេស រុស្ស៊ី ចិន . . ជាដើម យើងក៏នឹងរៀនដែរ ប៉ុន្តែរៀនគ្រាន់តែជាជីវភាសា (en tant que langue vivante) ដូចជាយើងរៀនភាសាអង់គ្លេសសព្វថ្ងៃតែប៉ុណ្ណោះ ។ បញ្ហានេះ ដំបូងមុខតែនឹងជួបការលំបាកខ្លះជាមិនខាន ជាពិសេសគឺសៀវភៅ នឹងសព្ទបច្ចេកទេស (les termes techniques) ។ ប៉ុន្តែការនេះមានអ្វីជាចម្លែក! នៅគ្រាដំបូងសាស្ត្រាចារ្យនឹងរៀបចំមេរៀនរបស់ខ្លួនដោយម៉ត់ចត់ បង្រៀនហើយរក្សាទុកមេរៀនទាំងនោះ ។ ក្នុងការសរសេរជាខ្មែរ ដំបូង មុខតែមានខុសគ្នាបន្តិចបន្តួចអំពីសព្ទ នឹងវចនសព្ទជាមិនខាន ប៉ុន្តែ សាស្ត្រាចារ្យគប្បីសង្កត់ឲ្យសិស្សយល់ជាពិសេសនូវអត្ថន័យនៃសព្ទនោះ ។ លុះមានពិសោធន៍ខ្លះៗ រៀងៗខ្លួនហើយ សាស្ត្រាចារ្យទាំងនោះអាចនឹងជួបជុំគ្នា ពិគ្រោះពិភាក្សាឬការពិសោធន៍គ្នាទៅវិញទៅមក អំពីការប្រែពាក្យក៏ដូចជាអំពីការរៀបចំមេរៀន នឹងអំពីវិធីបង្រៀន ។ ការនេះ សាស្ត្រាចារ្យអាចនឹងធ្វើឡើងនៅក្នុងវិស្សមកាល ឬនៅដំណាច់ឆ្នាំក៏បាន ។ ហើយដល់ពេលនោះ សាស្ត្រាចារ្យមុខវិជ្ជានិមួយៗ ក៏អាចនឹងចងក្រងសៀវភៅបន្តិចម្តងៗបណ្តើរៗ តាមការបង្រៀននឹងតាមការពិសោធន៍របស់ខ្លួនបានយ៉ាងល្អ ។

ប៉ុន្តែ ក្នុងចំណុចនេះ យើងបានទទួលដោយរីករាយនូវដំណឹងដែលថា ក្នុងការប្រជុំមួយនៃចាងហ្វាងវិទ្យាល័យ - អនុវិទ្យាល័យទាំងឡាយក្នុងឆ្នាំនេះ ក្រសួងអប់រំជាតិបានសំរេចឲ្យបង្រៀនប្រវត្តិវិជ្ជានិងភូមិវិជ្ជាជាភាសាខ្មែរក្នុងមធ្យមភូមិ ចាប់ពីឆ្នាំសិក្សាក្រោយនេះទៅ ។ ការនេះជាការប្រពៃណាស់ ។

◙

ដូចអស់មិត្តបានឃើញស្រាប់ គោលការណ៍នៃការកែទំរង់ខាងសិក្សាធិការ ដែលជាវិស័យមួយជាប់ជិតស្និទ្ធនឹងការពង្រីកសេដ្ឋកិច្ចនេះ សម្តេចឪទ្រង់សព្វព្រះរាជហឫទ័យគូសបញ្ជាក់យ៉ាងច្បាស់លាស់រួចស្រេចអស់ហើយ ។ ហើយនៅក្នុងសន្និសីទនោះ (១៤ ធ្នូ) ព្រះអង្គក៏ទ្រង់បានដាក់ការៈជូនសហជីវិនរដ្ឋលេខាធិការ កុរ - សុីអុយ និងសហជីវិន ជួង-សារិន នាយកមធ្យមសិក្សា «ឲ្យអញ្ជើញចាងហ្វាងនៃអាគារមធ្យមសិក្សាទាំងឡាយ ក្នុងព្រះបរមនាមរបស់ព្រះអង្គ ដើម្បីនឹងពិភាក្សាកែទំរង់កម្មវិធីសិក្សាតាមន័យ នៃសេចក្តីសំរេចចិត្តក្នុងឱកាសសន្និសីទនោះ» ថែមទៀតផង ។

សមាគមសាស្ត្រាចារ្យខ្មែរយល់ឃើញថា៖

ព្រះរាជយោបល់សម្តេចឪស្តីពីការកែទំរង់កម្មវិធីសិក្សានេះ ពេញជាស្របទៅនឹងកាលៈទេសៈជាពន់ពេក ! ហើយក៏ពិតជាមធ្យោបាយមួយដ៏ជាក់ស្តែង ជួយដល់ព្រះរាជនយោបាយកែទំរង់សេដ្ឋកិច្ច-ហិរញ្ញវត្ថុ !

ព្រះរាជវិធានការដែលព្រះអង្គបានបាត់ ដើម្បីនឹងសំរេចការកែទំរង់នេះ ក៏មុឺងម៉ាត់ !

ហើយសូមប្តេជ្ញាឧបត្ថម្ភព្រះរាជយោបល់នេះទាំងស្រុង ។

ជយោ ! ការកែទំរង់កម្មវិធីសិក្សា !

ជយោ ! ការកែទំរង់សេដ្ឋកិច្ចរបស់សម្តេចឪ !



## POUR UNE REFONTE TOTALE DE NOTRE ENSEIGNEMENT

Pour le succès de la réforme économique qu'il vient de lancer, notre Chef de l'Etat bien-aimé a daigné tracer les grandes lignes pour une refonte de notre enseignement.

Nos amis ont sans doute l'occasion d'entendre la conférence faite par Monseigneur, le 14 décembre 1963, dans ce sens, devant les responsables de l'Enseignement, et diffusée par la RNK.

Mais vu le caractère très actuel du problème, nous reproduisons le condensé de cette conférence.

◘

La présente réunion a pour but de me permettre de vous entretenir de questions très importantes qui intéressent l'avenir de notre jeunesse et par conséquent celui pe notre nation.

Comme vous le savez, nous avons lancé des réformes dans plusieurs domaines en particulier dans celui de l'économie pour réaliser dans les meilleurs délais notre indépendance économique sans laquelle notre pays ne peut que connaître des obstacles et des dangers de plus en plus grands sur sa route. Notre pays malgré les soulagements apportés dans certains domaines par l'aide américaine qui nous a été accordée depuis 12 ans n'est même pas arrivé à réaliser l'équilibre de son budget et de sa balance commerciale, et, dans le domaine économique, il faut reconnaître que notre retard est encore grand.

Dans le domaine de l'éducation nationale, domaine étroitement lié à celui de notre expansion économique puisque nous y avons pour tâche de préparer notre jeunesse aux lourdes charges qui l'attendent dans le cadre du redressement économique du pays, nous avons fait le maximum d'effort non seulement pour les élèves et l'expansion de l'infrastructure scolaire mais aussi pour le corps enseignant auquel nous avons accordé des avantages divers en particulier des salaires élevés.

Nous n'avons cependant pas réalisé nos buts à 100 % et ce en raison de difficultés diverses, celles notamment d'ordre financier qu'il nous faut résoudre à partir de notre expansion économique.

Vous savez bien que notre enseignement supérieur souffre aujourd'hui du manque de locaux et de divers autres moyens matériels. Je vous signale à ce sujet que nous sommes en train de construire, sur la route de Pochentong, un grand centre universitaire Sangkum, construction financée d'une part par des fonds que notre Banque Nationale a généreusement mis à ma disposition (environ 17 millions de riels) et d'autre part par notre Budget National qui contribuera pour un crédit de 60 millions.

A côté de ce problème de manque de locaux pour notre enseignement supérieur, qui sera résolu après l'achèvement de la construction du centre universitaire Sangkum, nous avons d'autres problèmes à résoudre.

Nous aurons par exemple, également dans le domaine de l'infrastructure scolaire à prendre en charge les réalisations financées sur l'aide américaine dans le domaine de l'enseignement technique, réalisations qui ont été interrompues par suite de la répudiation de cette aide et que nous devons poursuivre Nous avons en outre à développer notre enseignement secondaire qui actuellement ne comporte tout au plus 50.000 élèves contre un nombre de 600.000 élèves pour notre enseignement primaire. Il faudrait au moins que nous puissions offrir à nos jeunes, d'ici quelques années, 100 000 places dans nos établissements d'enseignement secondaire, c'est — à — dire le double du nombre actuel.

L'hebdomadaire «Réalités Cambodgiennes» a posé cette semaine la question de savoir si le gouvernement sera en mesure de garantir du travail pour toute la jeunesse qui sortira des écoles, si nos programmes scolaires tiennent compte de nos nouvelles réformes et s'ils ont été adaptés à ces réformes par nos responsables.

Depuis l'avènement de notre Sangkum, nous avons apporté à l'esprit et à nos programmes d'enseignement diverses modifications. Ainsi par exemple certaines disciplines ont été introduites qui n'existaient pas autrefois : par exemple les travaux manuels, certains travaux d'artisanat et d'atelier. Ces innovations ont pour but de permettre à nos futurs diplômés de ne pas être seulement des intellectuels purs mais de posséder en outre un certain nombre de connaissances pratiques.

Le journal que je viens de citer pose également la question de savoir si ces innovations sont suffisantes compte tenu du champ étendu des nouvelles réformes que nous avons adoptées. C'est la question que nous allons étudier aujourd'hui.

Il me semble en effet opportun d introduire dans nos programmes scolaires des activités économiques destinées à familiariser nos élèves avec la pratique de métiers qui concourent au développement économique du pays et par là même à leur offrir des débouchés qui s'avèreront utiles pour eux mêmes et pour leur pays. Ainsi par exemple nos élèves pourront pratiquer des cultures, de l'élevage, de l'artisanat. etc . . . et des coopératives pourront être créées dans nos écoles comme cela se fait dans certains pays communistes. On gagnera d'autre part à réduire le programme d'enseignement concernant certaines matières telles que l'histoire, la géographie, les lettres et les arts concernant les pays étrangers . . .

■

NDLR — Monseigneur invite ensuite nos responsables à prendre la parole et à donner leur avis sur cette nouvelle conception de notre enseignement national,

Sah, Phu Sy Uy, Secrétaire d'Etat à l'Education Nationale, signale que pour l'enseignement secondaire le Service Pédagogique a établi un programme d'enseignement nouveau sur le fonctionnement et l'exploitation des usines, sur les machines, etc... Il signale aussi qu'il était prévu sur l'aide américaine de l'équipement pour ateliers scolaires destiné à 14 de nos lycées dont 3 seulement ont été entièrement dotés de cet équipement.

Monseigneur demande que le Gouvernement recherche les moyens de se procurer l'équipement manquant pour équiper les autres lycées et mettre en application tout ce programme d'enseignement industriel pratique déjà élaboré.

Monseigenur demande aussi que la Sonexim importe le matériel nécessaire dont la dotation était prévue sur l'aide américaine.

Il charge également Sah. Phu Sy Uy et Duong Sarin de convoquer en son nom les Directeurs et Directrices de nos établissements scolaires pour mettre au point les nouveaux programmes scolaires à établir dans le sens des décisions prises au cours de la conférence.

Il leur recommande toutefois de prévoir, pour alléger les charges du Budget National, la participation des riches possédants qui pourraient venir en aide à notre enseignement en fournissant le matériel nécessaire. Il suffit pour cela que notre gouverneur de provinces et de municipalité fassent appel à la compréhension du secteur capitaliste privé qui par ailleurs a très bien assimilé nos nouvelles réformes et les exigences de notre nouveau socialisme.

Lors de l'ouverture du nouveau chantier de la voie ferrée Phnom-Penh — Sihanoukville, dit Monseigneur au village de Thammada, dans la province de Takèo, le gouverneur m'avait dit que le clergé et le peuple sont prêts à financer eux mêmes la construction des gares dans Takèo dès que le tronçon ferroviaire Phnom-Penh — Takèo sera mis en exploitation. J'ai dit à nos généreux moines et habitants de la province de ne pas s'occuper de la construction de ces gares qui ressort aux attributions de Sah. Nguon Chhay Kry devenu maintenant directeur général de la Société Nationale des Chemins de Fer Royaux, société autonome, mais de réserver l'argent qu'ils prévoient pour la réalisation de ces gares pour la construction de *nouveaux bâtiments scolaires.*

◘

Monseigneur précise que les programmes d'enseignement de mathématiques et de sciences seront maintenus et devront même être renforcés dans l'intérêt de notre jeunesse et de notre pays dont le développement économique aura à compter sur nos futurs techniciens du domaine scientifique.

Les réductions de programme porteront sur des matières telles que histoire, géographie, littérature surtout lorsque ces matières se rapportent à des pays étrangers. On ne retiendra aux programmes que l'essentiel, réduit au minimum indispensable, des faits historiques, des données géographiques et des notions de littérature qui s'avèreront indispensables pour un niveau de culture générale convenable.

Il ne faut pas par exemple que nos futurs hauts diplômés soient comme ces savants de Bombay (ils m'ont été introduits comme tels par le gouverneur de cette ville lors d'une réception offerte en mon honneur) qui ignoraient que le Cambodge possède une flotte aérienne et des aéroports pouvant recevoir des quadrimoteurs et

jets, que son Chef d'Etat fait des tournées en provinces dans des voitures, en hélicoptère ou en avion et non à dos d'éléphant, que les femmes khmères peuvent s'intruire comme les hommes et qu'elles ne passent pas leur vie à faire la cuisine et à laver la vaiselle.

Monseigneur signale en outre que beaucoup de petits métiers ayant un certain caractère technique, par exemple les ouvriers spécialisés des bâtiments ou d'électricité, sont exercés par des étrangers, vietnamiens surtout, et que nos nationaux ne reçoivent généralement que des emplois d'auxiliaire ou mêmes de simples coolies.

Nous, qui sommes de la race des bâtisseurs d'Angkor, race d'ingénieurs et d'architectes nous avons tué nos talents et notre génie à force de ne faire exclusivement ou presque qu'un travail de paperasserie comme nous y ont habitués les Français pendant près d'un siècle.

Il nous faut ranimer ces aptitudes endormies que nous tenons de nos ancêtres en prévoyant dans nos programmes scolaires l'enseignement des métiers techniques ou de précision assez rémunérateurs et qui sont exercés actuellement par une majorité d'étrangers.

Nous préparerons ainsi la voie à de nombreux débouchés pour notre jeunesse de demain et pour ce faire il n'y a pas lieu d'augmenter les heures de cours mais de réduire les heures d'enseignement de certaines autres matières.

Monseigneur insiste sur la nécessité de familiariser nos jeunes dès l'enseignement primaire avec les activités agricoles et commerciales et d'une façon générale avec les affaires. Les écoles auront leurs propres cultures. On y fera également de l'élevage et de l'artisanat. Les produits seront vendus avec l'aide éventuelle de l'OROC et surtout dans le cadre d'une organisation de vente appartenant en propre aux élèves qui constitueront les employés, les secrétaires, les comptables, les gérants de leur propre «Office» Les bénéfices seront partagés entre les élèves eux mêmes qui pourront ainsi subvenir plus facilement à leurs besoins scolaires et leurs dépenses perssonnelles.

Le gros avantage qu'on retirera de cet enseignement pratique inculqué à l'enfant dès son jeune âge est que celui-ci s'intéressera de plus en plus au travail de la terre et d'une façon générale aux nombreux métiers du secteur privé. Sortis d'école ils seront mûrs pour ces métiers vers lesquels ils seront irrésistiblement attirés. D'une part ce sera l'économie du pays qui en retirera un profit énorme, d'autre part ce sera l'envoûtement exercé par les emplois administratifs qui s'éteindra tout naturellement. Et ce sera aussi le grave problème du travail, qui commence à se poser de façon dramatique, qui aura trouvé la solution la meilleure.

(Applaudissements chaleureux de l'auditoire, composé essentiellement de Proviseur, Directeurs et Directrices de Lycées et Collèges, d'Inspecteurs et Directeurs de l'Enseignement Primaire).

in "La Dépêche du Cambodge" du 18 décembre 1963.

# L'ENSEIGNEMENT SECONDAIRE NATIONAL KHMER ET LA POLITIQUE AGRICOLE de SAMDECH SAHACHIVIN

**Kong Lomphon**

Nous sommes heureux de publier in extenso la lettre que nous a envoyée notre ami Kong Lomphon, directeur du Collège de Kompong-Thmâr, qui, à notre avis, apporte des contributions, si minimes soient-elles, à l'esprit de refonte de notre enseignement préconisée par Samdech Euv. Que notre ami Lomphon trouve ici nos vifs remerciements.

Tout le monde a constaté que l'agriculture est l'un des principaux piliers de la "deuxième indépendance" du monde actuel (I). Notre pays, indépendant, de dix ans, se prépare maintenant à sortir de la crise de croissance économique sous le dynamisme et la haute impulsion de notre Leader vénéré.

Son regard tourne surtout vers notre jeunesse et en particulier vers l'enseignement secondaire national du premier cycle, considéré jusqu'à présent comme source de jeunes énergies humaines.

Dans cette rubrique, mon point de vue — il n'est pas nouveau peut-être — se classe en deux parties assez nettes :

— introduction du programme d'agriculture dans l'enseignement secondaire national.

— orientation préliminaire des élèves vers l'agriculture d'abord – section d'agriculture – puis vers l'industrie et le commerce ensuite.

## I. Introduction du programme d'agriculture dans l'enseignement secondaire national

Devant la conjoncture actuelle de notre pays en matière de politique économique nouvellement adpotée par Samdech, Chef de l Etat, j'ai cru pouvoir remarquer que l'enseignement secondaire national ne devra pas rester indifférent à l'égard de ces évènements fondamentaux qui vont donner une forme nouvelle et originale (socialisme national bouddhiste) à la politique générale du Cambodge.

Il (l'enseignement secondaire) doit contribuer ses efforts, si minimes soient-ils, au développement et à la prospérité de notre agriculture nationale. Si un établissement secondaire quelconque, illimité dans l'espace et dans le temps, ne peut participer activement à la "croisade de production concrète", il peut néanmoins, apporter son aide et son soutien moraux partout où il le juge utile et nécessaire.

## A. Campagne d'inculcation de l'agriculture

Puisque le gouvernement royal a prévu un plan de campagne générale de l'agriculture à travers le Royaume tout entier, il ne sera pas malvenu aux chefs des établissements secondaires de porter leurs efforts dans le même sens, suivant leurs rayons d'action respectifs

En effet, ils pourront envisager une coopération avec le service d'agriculture local pour qu'il leur apporte son concours dans l'ordre tant théorique que pratique, à savoir : cours en commun aux étudiants (méthodes de culture, d'élevage, et de préservation contre les maladies de divers plants, animaux ou volailles . . .). Ces cours pourront bien avoir lieu une ou deux fois par mois dans l'enceinte de l'établissement, sous forme de congrès ou de causeries.

Du côté technique de l'enseignement, ceci n'a pas d'inconvénient. Le chef de l'établissement pourra réserver à cet effet ou bien les heures libres ou bien les heures d'éducation physique ou bien enfin celles de travail manuel. Les parents d'élèves y seront cordialement invités.

Ensuite, lorsque cours est suffisamment donné, il faudra passer à l'application pratique.

## B. L'application pratique

Pour les lycées et les collèges provovinciaux ou communaux, il n'est pas impossible aux Proviseurs ou Directeurs de trouver quelques parcelles de terre – $\frac{1}{2}$ ha au moins (dans l'enceinte même) — pour en faire des pépinières ou terrains de cultures. Ils pourront transformer, par exemple, l'une des trois heures d'éducation physique en "éducation physique - agriculture".

Si un établissement en question a sept classes, donc il y aura bien une heure de disponible tous les jours, l'on verra que notre culture scolaire pourra être déjà travaillée une fois par jour. Mais un établissement secondaire du premier cycle complet (de 6ème à 3ème) comprend à peu près de 12 à 20 classes; dans ce cas, notre terrain de culture sera travaillé deux ou trois fois par jour. Dans ces conditions la récolte s'avèrera bonne (dans ces jardins potagers, l'on trouvera : canne à sucre, bananier, choux, navet; bref toutes les cultures saisonnières et maraichères, et selon la vocation du terrain).

Ainsi les élèves apprennent et savent comment on cultive telle ou telle plante et enfin ils aimeraient l'agriculture. La difficulté et l'échec ne résident pas dans "ne pouvoir faire" mais plutôt dans "ne pouvoir bien faire". Or il suffit de *vouloir pour bien faire.*

Le revenu de cette "éducation physique – agriculture" sera utilisé à acheter des matériels sportifs et des livres classiques pour la collectivité scolaire.

Si tous ces résultats se confirmaient positifs, il serait opportun d'aller encore plus loin, c'est-à-dire jusqu'à l'orientation préliminaire des élèves en direction de l'agriculture, section d'agriculture dès leur entrée en 6ème

## II. ORIENTATION PRELIMINAIRE DES ELEVES VERS L'AGRICULTURE — SECTION D'AGRICULTURE

Si "l'application pratique" mentionnée ci-dessus ne semble pas aussi épineuse, il n'en est pas de même pour l'orientation préliminaire des élèves et ceci parce que notre pays ne dispose pas encore suffisamment de professeurs psycho-pé-

dagogues. Cependant rien ne nous empêche d'y parvenir; nous laissons les élèves libres à disposer d'eux-mêmes; ils auront à choisir entre les diverses sections : section générale (pour ceux qui espèrent continuer leurs études jusqu'à l'université - Lettres - Droit - Médecine . . .), section agricole, section industrielle, section commerciale, . . . Dans ce choix d'une importance capitale, nous pourrons espérer qu'il y ait intervention des parents, lesquels ne laissent pas leurs fils décider seuls. Ils orientent aussi les leurs.

De toute façon, si succès il y a, nous pourrons bien attendre quelques bienfaits dont les principaux sont les suivants :

intérêts personnels de l'élève

— valeur professionnelle du futur agent de l'Etat d'une part, et avantage de l'administration d'autre part.

## A.— Intérêts personnels de l'élève

Ayant déjà acquis ces connaissances et en particulier celles sur l'agriculture, et ce "savoir-faire" depuis la période de la pré-adolescence (pendant 4 ans - de 6ème à 3ème), le jeune homme ne sera pas complètement nu et désarmé, à la sortie du collège après l'echec à l'examen du diplôme — pour faire face à la lutte pour la vie. Il pourra débrouiller à son village natal, sur son héritage encestral agraire, pour mener un genre de vie pleine de promesses. Pendant le cycle scolaire, il a eu dans sa conscience le fameux mot "agriculture" qui s'enracine dans sa pensée, et dont le sens et la valeur lui sont inséparables du coeur.

Jusqu'à présent il faut accepter franchement que les 95 % de nos jeunes collégiens n'ont pas pensé à autre chose qu'à devenir bureaucrates. Si cet état d'esprit hante toujours nos jeunes, il est sûr que notre société de demain sera malade. Combattre cette maladie ou plutôt cette "bureaucratomanie" reste un devoir majeur du corps enseignant. Prévenir vaut mieux que guérir; et encore il faut prévenir à temps. Maintenant le temps arrive.

## B. Haute valeur professionnelle et avantage de l'administration

La section agricole étant suppossée réalisée à côté des autres sections, au moins à côté de la section générale. Désormais l'Etat ne pourra recruter ses agents ou fonctionnaires que parmi les élèves de la section correspondante. Ainsi nous pourrons espérer qu'ils auront évidemment une valeur professionnelle plus élevée (2). D'autre part, l'Etat semble raisonnable dans le mode de recrutement.

Au lieu d'avoir 8.000 candidats pour un concours quelconque, il n'y en aura que 1.000 ou 1.500 seulement d'où l économie sur les rémunérations aux examinateurs. Enfin, comme il n'y a pas trop de candidats échoués (par rapport à précédemment), il n'y aura pas du même coup trop de jeunes promeneurs chômeurs dans les belles avenues et les splendides jardins de Phnom-Penh.

Voilà, à mon avis, l'un des meilleurs moyens de bien utiliser les sources de jeunes énergies humaines, et l'un des procédés d'opération sans douleur pour notre jeunesse.

Le corps enseignant tout entier est très soucieux devant le problème de l'avenir de la jeunesse estudiantine.

Vive la politique agricole de SÂMDECH SAHACHIVIN !
Vive la nouvelle politique économique du PRINCE !
Vive l'orientation préliminaire des élèves !
Vive l'agriculture scolaire !

Kong Lomphon
Prof. d'Histoire

---

(1) J'entends par là tous les pays nouvellement indépendants et sous-développés. Pour l'expression : "deuxième indépendance", je la dois à M.U.V.

(2) Je n'ai pas voulu dire que Messieurs les agents ou contrôleurs d'agriculture ont une valeur professionnelle moindre.

★

ដំណឹងល្អ ចំពោះសាស្ត្រាចារ្យរូបសាស្ត្រ

មានសៀវភៅថ្មីឈ្មោះថា «Travaux scientifiques expérimentaux» (premier cahier)

ស្ដីអំពីរបៀបធ្វើការពិសោធន៍ងាយៗ ខាងរូបសាស្ត្រ ដើម្បីទំលាប់សិស្សថ្នាក់តូចៗ ឲ្យចេះពិចារណា និងស្រាវជ្រាវ ។

បើមិត្តចង់បាន សូមសរសេរទៅសុំ specimen អំពី អាសយដ្ឋាននេះ

Classiques Hachettes
79. boulevard Saint-Germain, Paris 6e

គេនឹងផ្ញើជូន មួយលេខមកពិនិត្យសាកមើល ។

## LES POSSIBILITÉS DE NOTRE LANGUE NATIONALE

**Hu Nim**

La langue cambodgienne comme les autres langues, se développe, s'enrichit. Issue d'uue langue originale «Le Mônkhmer», pratiquée dans le Bas Birmanie et tout le Bassin du Ménam et du Mékong quelques siècles avant notre ère, la langue cambodgienne a subi de grandes influences des deux langues dont elle est en quelque sorte «la synthèse» : le sanscrit et le pali.

On sait que le sanscrit, langue littéraire classique de l'Inde, appartient à la famille des «langues indo-européennes». C'est-à-dire qu'il a la même origine que les langues classiques françaises, le grec et le latin.

C'est un bourgeon, comme a dit M. François Martini, «de la même souche d'où sont sorties les langues slaves germaniques, baltiques».

Ce fut approximativement à l'époque de Founan que le sanscrit s'introduisit au «Kambuja» avec le Mahayana (Grand Véhicule) et le Brahmanisme. On pouvait dire que le «Ream Ker» équivalent en Khmer de l'épopée indienne du «Rmâyana qui n'était en réalité qu'une inspiration brahmanique, est un exemple typique de l'influence sanscrit dans notre littérature. Sans connaître le sanscrit, il est dificile de comprendre les termes utilisés dans le «Ream Ker», lesquels sont soit d'origine sanscrit soit d'ancien Khmer.

PLUS TARD, au début du XVè siècle, lorsque le Hinayan (Petit Véhicule) dont les textes sacrés sont en pali eût remplacé à la fois le Brahmanisme et le Mahayana, note langue acquit un lot important de pali. Cet enrichissement du lexique khmer par emprunt au pali se fait chaque jour Nos anciens poèmes nous en apportent la preuve Nous pouvons citer quelques uns écrits principalement sur olles et où les termes pali et sanscrit se mêlent avec les termes proprement khmers :

«Preah Leaks Sinnavong» ou le Prince Leaks Sinnavong ;
«Sain Sila Chey» ou Sain Séla le victorieux ;
«Suvann Kdam Sâr» ou la Crabe blanche dorée ;
«Ratana Vong» ou le prince Ratana Vong ;
«Tuk Ream Phka Ream» ou L'eau qui danse, la fleur qui danse ;
«Neang Pir Dandab» ou Les 12 filles.

La liste sera longue si nous faisons de recherches, car notre littérature est très riche. Tous en poèmes. Or pour les composer, nos anciens écrivains, afin d'une part de rendre plus agréables et plus savantes les expressions qu'ils ont utilisées et d'employer le vocabulaire royal (Reach Sap) — presque tous les poèmes se rapportaient aux aventures des «monarques ou princes» que symbolisent les «hommes» en face des démons «géants ou Yeak», soit le bien contre le mal – de l'autre, ont recours aux mots pali ou sanscrit. Il est à noter que pour former un «Reach Sap» ou désigner tout ce qui se rapporte aux rois, il suffit essentiellement d'utiliser les termes pali ou sanscrit en ajoutant «Preah» ou «Truong». Par exemple le mot «main» : en terme royal nous disons soit «Preah Hâsth» (sanscrit) soit «Preah Hattha» (pali). Par ailleurs, les termes pali ou sanscrit sont généralement utilisés par nos écrivains chaque fois qu'ils ont besoin de compléter la rime ou la rendre plus savante. Pour désigner «la forêt» par exemple ils emploient plutôt «Aranh» (sanscrit) ou «Aranya» (pali) même mixte «Proeuks Prey» (sanscrit et khmer) que «Prey» tout court qui est purement khmer.

Personne ne nie que la langue française est devenue une langue savante et universellement exprimable grâce aux latin et grec. Cela est normal comme doit l'être notre langue grâce aux pali et sanscrit. Toutes ces langues ont la même source «aryenne» qu'on désigne par le groupe «indo européen».

PENDANT la période coloniale, notre langue tomba en décadence. A part quelques codes en particulier «Pénal et procédure pénale» dont la traduction est nécessaire pour imposer l'ordre à nos compatriotes de cette époque, notre littérature s'effondra.

A peine le Cambodge eut-il retrouvé son autonomie et surtout son indépendance complète en 1953 que notre langue se réveille avec la conscience nationale et se développe prodigieusement.

La nécessité de traduire les textes administratifs, juridiques et constitutionenls déclencha donc depuis 1945 un mouvement de rénovation et d'enrichissement. La Commission Culturelle est née à cette époque. Ayant au départ la tâche essentielle de traduire la Constitution dont le projet est rédigé en français, cette Commission se vit étendre de plus en plus sa compétence. Composée d'éminents intellectuels bouddhistes dont le sage Samdech Sangharaj Chuon Nat, l'auteur des deux tomes de Dictionnaire Khmer et Preah Krou Pôthiveang Huot Tat qui ne cessent de donner à notre langue leur précieuse contribution ainsi que quelques lettrés de l'Institut Bouddhique, la Commission a joué et joue un rôle extrêmement important dans le développement de la langue khmère actuelle. Depuis, cette dernière se modernise et s'enrichit davantage.

Aussi les travaux de la Commission Culturelle permettaient-ils de traduire — en quelque sorte «nationaliser nos lois et règlements» — un grand nombre de textes officiels employés dans la période coloniale. Aujourd'hui encore elle continue à traduire les termes techniques sur la demande des services intéressés qui ont besoin de présenter à la chambre des projets de loi. Car selon les dispositions mêmes de notre Constitution ces dernières doivent être en Khmer. Il suffit de comparer la période actuelle à celle du protectorat pour se rendre compte de l'ampleur accompli par notre Sangkum dans ce domaine.

La tâche de la Commission n'est pas terminée. Elle n'est en principe qu'un commencement. Car devant elle, se dressent de grandes perspectives qui devront rehausser notre langue à la hauteur des autres tout au moins dans cette partie de l'Asie **Notre avenir réside non en langues étrangères mais en notre propre langue.** Ceci ne veut pas dire que nous devons négliger les premières, au contraire ces langues étrangères en particulier le français et l'anglais doivent être attentivement soutenues et comprises dans nos programmes scolaires. Seulement notre attention doit porter également sur notre langue. Chaque année une importante quantité de devises est sortie pour l'achat des manuels scolaires qui sont tous en français. Le degré de culture comme celui de connaissances techniques dépend non des langues étrangères mais des programmes et comme Samdech Aou l'a souligné à plusieurs reprises des travaux pratiques ou exactement de l'assimilation rapide des connaissances théoriques nécessaires pour les applications pratiques. Ainsi les expériences réalisées par certains pays de l'Asie tels que la Corée, la Chine et la Réqublique Démocratique du Viet-Nam nous en fournissent la preuve. Les manuels scolaires depuis ceux des classes primaires jusqu'aux universités sont en langue nationale et ce, pour n'importe quels programmes : sciences, mathématiques, physique, chimie, etc.. Lors des visites d'une classe secondaire en ouvrant des manuels, nous constations que tout est en coréen, chinois ou vietnamien sauf les formules chimiques. Bien entendu les graphiques ou les figures de géométrie sont les mêmes que partout. Certaines dénominations sont même simplifiées. «On nationalise quelquefois certaines expressions», dit un professeur, mais la formule scientifique universellement usitée reste inchangée. Il s'agit, dit on, d'une simple convention.

Quant aux langues étrangères, elles sont enseignées dans des Instituts spécialisés. L'Univetsité de Pékin par exemple qui dispose de plus de I7 Facultés (Physique, Chimie, Biologie, Métallurgie, etc) comprend une Faculté de langues orientales à côté de celle de langues occidentales.

Quant aux connaissances techniques, on oriente les étudiants vers les travaux pratiques, les expériences ou recherches dans les laboratoires ou dans les ateliers des usines. Dans les campagnes, les élèves participent même aux travaux des champs et des rizières où ils étudient sur place l'application pratique de leurs leçons de science naturelle.

Certains programmes sont même plus avancés: à la classe de 5 et de 4ème, on étudie déjà l'électricité ou l'optique.

Notre langue offre donc de grands avantages. Son développement est très nécessaire surtout pour réaliser la réforme de la structure de notre enseignement que Samdech Sachivin a recommandée maintes fois et dont le Congrès National a déjà tracé les grandes lignes. Dernièrement, le I4/12/63, encore devant les représentants du corps enseignant Samdech Sahachivin a tracé d'importantes lignes de réforme à laquelle notre service compétent doit immédiatement procéder pour adapter l'enseignement aux impératifs imposés tant par nos besoins que par nos réformes sur le plan économique.

Dans cette tâche, la Commission Culturelle peut jouer un grand rôle. Or dans l'état actuel, de l'avis même de Preah Krou Pothiveang Huot Tat Vice Président de la Commission, cette dernière n'est pas «permanente» et ne fonctionne qu'une ou deux heures par jour. «Elle ne fait que traduire, dit le vénérable, les termes demandés par les services techniques quelconques. L'absence

d'un secrétariat permanent n'a pas permis la publication régulière et d'une façon uniforme les mots ou expressions qui ont été déjà traduits. D'autre part les personnalités qui connaissent bien les termes techniques français ne participent pas souvent aux travaux de la Commission soit parce qu'ils sont pris par d'autres affaires soit parce qu'ils ont des avantages plus importants en donnant des cours dans les établissements publics ou privés qui leur accordent des indemnités d'après le barème officiel.

Aussi nous permettons-nous de formuler des suggestions suivantes :

*Primo* : la Commission culturelle devrait :

1.— fonctionner d'une façon permanente

2.— avoir un local propre (jusqu'ici elle a fait plusieurs déplacements : du Ministère au siège de l'Assemblée, puis de l'Assemblée à l'Université bouddhique) et un Secrétariat permanent avec tout le personnel nécessaire;

3.— avoir un programme précis qui sera élaboré par elle en tenant compte de l'ordre de priorité;

4.— publier en son nom tous les termes ou expressions traduits par elle (La vente de ces documents pourra apporter des recettes importantes). Les recueils de la Commission doivent être utilisés par tous les organismes nationaux. Seules les traductions données par la Commission Culturelle sont valables pour les textes officiels.

*Secondo* : pour la traduction et la rédaction des manuels scolaires, il est souhaitable que la Commission compétente — dont la composition sera élargie par la participation des éminents professeurs — ait davantage de pouvoirs et mobilise tous les moyens à cette fin.

**Si nous portons toute notre confiance en notre langue non seulement « le sens natonal » se réveille, mais également la culture et les connaissances technique et scientifique de notre jeunesse se développent plus rapidement ce qui répondra bien à la cadence de cette époque. En plus, la réforme de la structure de notre enseignement, recommandée par Samdech Sahachivin, notre Père des deux Indépendances qui tient à cœur de l'avenir de notre jeunesse, n'aura de succès que si notre service compétent comprend l'importance de la langue nationale.**

**Hu Nim**

✶

មិត្តតំណាង ដែលមិនទាន់បានទទួលទស្សនាវដ្ដី សូមឲ្យដំណឹង!

# សំលៀកបំពាក់សមរម្យ

## ជាលំអនៃសិស្សយើង

ឈុច រិន

យើងយល់ថា មតិដែលមិត្ត ឈុច រិន បានបំផុសនេះ ប្រសិនជាធ្វើទៅបាន នឹងនាំផលប្រយោជន៍មកដល់សិស្សច្រើន ដូចជាមិត្ត ឈុច រិន បានរៀបរាប់ស្រាប់ ។ ប៉ុន្តែ យើងក៏យល់ថា បញ្ហានេះមិនមែនជាបន្ទាន់ទេ ព្រោះសិស្សានុសិស្សក្នុងមធ្យមភូមិ បើនិយាយឲ្យជាប់នឹងកាលៈទេសៈសព្វថ្ងៃនេះ ; បញ្ហាបន្ទាន់ គឺបិតនៅត្រង់ធ្វើយ៉ាងណាឲ្យយុវជនទាំងនោះបានជ្រួតជ្រាបគោលបំណងថ្មី នៃការសិក្សាអប់រំនៃសម្តេចឪ ទើបនឹងបានអំពាវនាវថ្មីៗនេះ ពោលគឺសិក្សាអប់រំដើម្បីស្ថាបនាសេដ្ឋកិច្ចជាតិ ដែលព្រះអង្គទើបនឹងបានដាក់ចេញនេះឯង (ទស្សនាវដ្តី សាស្ត្រាចារ្យ) ។

នៅសាលាបឋមសិក្សា ជាពិសេសនៅសាលាបឋមសិក្សារាជធានី សិស្សានុសិស្សស្លៀកពាក់ឯកសណ្ឋាន ទៅសាលារៀនរាល់ថ្ងៃ ។ ការស្លៀកពាក់របៀបនេះ សមរម្យណាស់ ។ ជនានុជននាំគ្នាសរសើរស្ទើរមិនដាច់ពីមាត់ ។

ក៏ប៉ុន្តែ គេបានសង្កេតឃើញថា សិស្សនៅមធ្យមសិក្សា ស្ទើរតែទាំងអស់ក្នុងប្រទេស បែរជាបោះបង់ចោលនូវរបៀបស្លៀកពាក់យ៉ាងល្អនេះទៅវិញ ។ គេប្រទះឃើញ សិស្សខ្លះតាក់តែងកាយឆើតឆាយក្រៃៗ ឬធ្វើត្រាប់តារាកុន ឯពាក់អាវប្រឡេះឡេវមួយ–ពីរផងក៏សឹងមាន ។ សិស្សខ្លះទៀត បែរជាខ្ជីខ្ជាព្រងើយកន្តើយ មិនរវីរវល់នឹងស្លៀកពាក់ឲ្យសមរម្យសោះ (សមរម្យមិនមែនបានន័យថាថ្មីៗ ឬថ្លៃៗទេ) ។

តើការស្លៀកពាក់នឹងបង្កើតនូវផលវិបាកយ៉ាងណាខ្លះ ដល់សិស្សយើង ?

មុនដំបូង ខ្ញុំសូមសាកល្បងនឹងអធិប្បាយពីផលល្អ នៃការស្លៀកពាក់ស្អាតនឹងសមរម្យ ជាមុនសិន ។

មិត្តអ្នកអាន នឹងយល់ស្របជាមួយខ្ញុំថា សិស្សទាំងឡាយត្រូវតែស្លៀកពាក់ឲ្យបានស្អាតបាតជានិច្ច ។ សិស្សមិនមែនធ្វើការក្នុងទីមិនស្អាត ហើយទៀងតែនឹងប្រឡាក់ភក់ដី គ្រឿងសៅហ្មងផ្សេងៗ ហេតុនេះស្លៀកពាក់យ៉ាងណាក៏បានដែរនោះទេ ។ សិស្សក៏មិនមែនជាអ្នកដែលដើរស៊ីផឹក រាំរែក ចង់ស្រី.. ហេតុនេះ ត្រូវតែតាក់តែងពង់កាយឲ្យឆើតឆាយ ដើម្បីទាក់ទាញចិត្តស្រីញី – នោះក៏ទេដែរ ។

ការពិត សាលារៀនជាទីស្អាតនឹងទីថ្លៃថ្នូរ ។ សាលារៀន មិនមែនកខ្វិកកខ្វក់មានធូលីដីដូចស្រែចំការ កំពង់ផែ ឬ រោងចក្រទេ ។ សាលារៀនក៏មិនមែនជាផ្លូវថ្នល់ ជារោងកុន រោងមហោស្រព ជាបារ ដែលជនចំពូកខ្លះនាំគ្នាចូលទៅ ដើម្បីនឹងក្រេបនូវកាមសុខ ផ្សេងៗឡើយ ។ ដូច្នេះ ទីនេះពុំមែនជាការដ្ឋាន ជាកន្លែងប្រឡងរូបឆោមលំអជាទីដែលគេមកអួតអាងពីសំលៀកបំពាក់ ឬ ទ្រព្យសម្បត្តិសោះឡើយ ។

ផ្ទុយទៅវិញ សាលារៀន ជាពិសេសអនុវិទ្យាល័យ – វិទ្យាល័យយើង ជាទីកន្លែងសិក្សា នឹងអប់រំ ។ ទីនេះ គឺជាកន្លែងដែលសិស្សចូលមកដើម្បីរៀនសូត្រ នឹងដើម្បីអប់រំ ចិត្តខ្លួនឲ្យកាន់តែចេះដឹងនឹងត្រឹមត្រូវ រមទម ស្លូតបូត មួយថ្ងៃបន្តិចៗ ខ្ទាំងឡើងៗ រៀងរហូតទៅ ។ ម្យ៉ាងទៀត គួរបញ្ជាក់ថា ការស្លៀកពាក់ស្អាតត្រឹមត្រូវសមរម្យនេះ គឺជាការគោរពចំពោះខ្លួនឯង ។

សិស្សណាស្លៀកពាក់ស្អាត នឹងត្រឹមត្រូវ សិស្សនោះជាអ្នកស្គាល់នូវតម្លៃរបស់ខ្លួនជាសិស្ស ជាយុវជនចេះដឹង សុភាពរាបសារ ។ ជាការពិតណាស់ ខ្លឹមសាររបស់មនុស្សស្ថិតនៅលើសន្តានចិត្តផងដ៏ល្អ ខាងក្នុង ។ ប៉ុន្តែ ការស្លៀកពាក់ស្អាតបាតត្រឹមត្រូវ ក៏ជាហេតុញុំាងឲ្យសេចក្ដីល្អ សីលធម៌ខាងក្នុងកាន់តែល្អឡើងៗដែរ ។ សំពត់ព្រែកាម៉ី ស្អាត ដែលគេយកទៅខ្ចប់រតនវត្ថុ អាចជួយធ្វើរតនវត្ថុឲ្យកាន់តែមានរស្មី

ល្អឡើងៗ បានយ៉ាងណា ការស្លៀកពាក់គ្រប់ដណ្ដប់ សន្ដានចិត្តល្អ ដោយសំលៀកបំពាក់ស្អាត និង សមរម្យ ក៏នឹងអាចជួយធ្វើឲ្យសន្ដានចិត្តកាន់តែល្អវិសេសឡើងៗ ជាលំដាប់ពុំខានយ៉ាងនោះដែរ ។

ផ្ទុយមកវិញ មាស ពេជ្រ ហាក់ដូចជាថមថយពន្លឺរស្មីបាត់តម្លៃខ្លះ បើប្រសិនជាគេយកក្រណាត់ខ្មៅគខ្វក់ទៅខ្ចប់ ។ យ៉ាងណាមិញ សិស្សឬជនចេះដឹងល្អត្រឹមត្រូវ បើបែរជាទៅស្លៀកពាក់មិនសមរម្យ ខ្ជីខ្ជា ឬស្លៀកពាក់តាមពួកជន “អ្នកមិនសមរម្យ” វិញ សិស្សនោះ ជននោះក៏នឹងខាតកិត្តិយស ហើយនឹងទៅជាវត្ថុនៃការខ្វាចនឹងការមិនចូលចិត្តនៃជនានុជន ពុំខានឡើយ ។

មិនគ្រាន់តែជាការគោរពចំពោះខ្លួនឯងប៉ុណ្ណោះទេ ការស្លៀកពាក់ស្អាតល្អសមរម្យ គឺជាការគោរពចំពោះអ្នកដទៃផងដែរ មានមិត្តភក្ដិទាំងស្រីទាំងប្រុសជាដើម តែជាពិសេសគឺចំពោះសាស្ត្រាចារ្យនឹងសាលានេះឯង ។

មិត្តជ្រាបស្រាប់ហើយថា កាលណាយើងត្រូវការចូលទៅជួបនឹង ‘‘អ្នកធំ„ ម្ដងៗ យើងរមែងតែងតែរៀបចំខ្លួនប្រាណ សំលៀកបំពាក់យើង ឲ្យបានរៀបរយត្រឹមត្រូវ ។ យើងធ្វើដូច្នេះ គឺយើងធ្វើដើម្បីគោរព „អ្នកធំ„ នោះ ។

មើលចុះ សាស្ត្រាចារ្យទាំងឡាយ លោកតែងតែស្លៀកពាក់ស្អាតសមរម្យណាស់ មុននឹងទៅបង្រៀនសិស្ស ។ សិស្សក្មេងជាងលោក តូចជាងលោក ហើយមកពឹងពាក់លោកដើម្បីឲ្យបង្រៀនផងក៏មែនពិត តែលោកក៏នៅតែស្លៀកពាក់ស្អាត និងសមរម្យជានិច្ចដដែល ។ លោកធ្វើយ៉ាងនេះ គឺលោកគោរពសិស្សរបស់លោក ដែលមានចំនួនយ៉ាងច្រើន ហើយជាពិសេសគឺលោកគោរពតម្លៃអត្តភាពមនុស្សត្រឹមត្រូវល្អ ដែលមាននៅក្នុងរូបសិស្សទាំងឡាយរបស់លោក ។

ដូច្នេះ សំលៀកបំពាក់ស្អាតត្រឹមត្រូវនៃសិស្ស ក៏ជាសញ្ញានៃការគោរពចំពោះគ្រូបាធ្យាយមួយដែរ ។

មិនតែប៉ុណ្ណោះ គេចំណាំសង្កេតឃើញថា សិស្សណាស្លៀកពាក់ស្អាតត្រឹមត្រូវ សិស្សនោះច្រើនតែជាសិស្សដែលមានសៀវភៅស្អាត មានកិច្ចការធ្វើដោយស្អាតល្អត្រឹមត្រូវ ។ បើនិយាយពីអនាម័យវិញ សំលៀកបំពាក់ស្អាតជួយកំចាត់ជម្ងឺផ្សេងៗពីសិស្សថែមទៀតផង ។

អាស្រ័យហេតុនេះ ការស្លៀកពាក់ស្អាតដោយសមរម្យនៃសិស្ស គួរតែត្រូវគេយកចិត្តទុកដាក់ឲ្យណាស់ ។

## ▣ អំពីឯកសណ្ឋានសិក្សា

សាលាទីមួយៗ សុទ្ធតែមានឯកសណ្ឋានប្រចាំសាលារៀងៗខ្លួន ។ ប៉ុន្តែឯកសណ្ឋាននេះ សិស្សអាចនឹងស្លៀកពាក់បានតែនៅថ្ងៃបុណ្យណាមួយ ដែលសាលាតម្រូវឲ្យស្លៀកពាក់តែប៉ុណ្ណោះ ។ ក្រៅពីថ្ងៃនេះគឺរាល់ថ្ងៃសិក្សា តាមធម្មតា សិស្សស្លៀកពាក់តាមចំណង់របស់ខ្លួន ។

ឯកសណ្ឋានសិក្សា ខុសគ្នាពីឯកសណ្ឋានសាលា ។ ឯកសណ្ឋានសិក្សា សិស្សស្លៀកពាក់មករៀនរាល់ថ្ងៃ ។ រីឯឯកសណ្ឋានសាលាវិញ សិស្សស្លៀកពាក់នៅថ្ងៃបុណ្យណាមួយ ដែលសាលាតម្រូវឲ្យស្លៀកពាក់តែប៉ុណ្ណោះ ។ ការស្លៀកពាក់យ៉ាងនេះ នឹងអាចជួយបំបាត់នូវការចាញ់ប្រៀបគ្នាខាងផ្លូវទឹកចិត្ត នឹងខាងផ្លូវប្រាជ្ញា បើមិនបានទាំងអស់ យ៉ាងហោចណាស់ក៏បានខ្លះៗដែរជាពុំខាន ។ ម្យ៉ាងទៀត ការស្លៀកពាក់ស្អាត ហើយដូចគ្នាយ៉ាងនេះ ជាលំអ ជាកិត្តិយសរបស់សាលា នឹងរបស់ប្រទេសជាតិថែមទៀតផង ។

តើសាស្ត្រាចារ្យទាំងឡាយនឹងសប្បាយយ៉ាងណាទៅ បើសិស្សរបស់លោកស្លៀកពាក់ស្អាត ដូចៗគ្នា ហើយញញឹមញញែមសប្បាយចិត្តនឹងរៀនសូត្រ លែងគិតពីអួតអាង ឬ អាក់អន់ ពីរឿងស្លៀកពាក់យ៉ាងនេះ? តើប្រទេសជាតិយើង ថ្ងៃក្រោយនឹងរុងរឿងចំរុងចំរើនប៉ុនណាទៅ បើអនាគតពលរដ្ឋទាំងឡាយចេះស្លៀកពាក់ត្រឹមត្រូវ ចេះស្រឡាញ់សាមគ្គីសាមគ្គា យោគយល់គ្នា តាំងតែពីនៅជាយុវជនតូចតាចយ៉ាងនេះទៅហើយ?

មិត្តទាំងឡាយនឹងបញ្ឈប់សំដីខ្ញុំត្រឹមនេះ ដើម្បីបញ្ជាក់ប្រាប់ខ្ញុំថា: “ការនិយាយអធិប្បាយជាការងាយស្រួល ប៉ុន្តែការអនុវត្តវិញ មិនមែនជាការស្រួលសោះឡើយ ។ ខ្ញុំក៏យល់ថា ការអនុវត្តនេះពិតជាការពិបាកមែនហើយ ប៉ុន្តែខ្ញុំពុំជឿថាវាជាការមិនអាចសម្រេចបាននោះឡើយ បើពិតជាមានឆន្ទៈនឹងធ្វើមែន ។ គេអាចនឹងអំពាវនាវដល់សិស្សដែលមានសំលៀកបំពាក់រិចរិលហើយ ហើយដែលត្រូវការទិញសំលៀកបំពាក់ថ្មី ឲ្យទិញសំលៀកបំពាក់ជាឯកសណ្ឋានតែម្តង ។

ខ្ញុំសង្ឃឹមថា មិត្តអ្នកអាននឹងជួយរិះគន់ផ្តល់យោបល់ដល់ខ្ញុំជាពុំខាន ។

(យោបល់ផ្សេងៗ សូមផ្ញើទៅ ផុប រិន នៅអនុវិទ្យាល័យតាខ្មៅ កណ្តាល)

សូមអរគុណជាមុន

★

## មិត្តតំណាង!

បើមានដំណឹងអ្វីទាក់ទងនឹងមិត្តសមាជិក ស.ស.១. ក្នុងមណ្ឌលមិត្ត ដែលមិត្តឯទៀតៗ គួរដឹង សូមមិត្តបញ្ជូនមកឲ្យគណៈកម្មាធិការនាយក បានដឹងផង ។

# កិច្ចការសមាគម

នៅក្នុងឱកាសពិធីចំរើនព្រះជន្មសម្តេចឪគំរប់ ៤១ ព្រះវស្សា គណៈកម្មាធិការនាយក នៃ ស.ស.ខ បានអនុម័តសារលិខិតថ្វាយព្រះពរមួយច្បាប់ ដែលមិត្តយើងអាចនឹងអាន អត្ថបទទាំងស្រុងបាននៅជិតនេះ ។

★

ប៉ុន្មានថ្ងៃក្រោយពីការសម្ពោធអាគារព្រះសីហនុ នៅក្នុងបរិវេណនៃពុទ្ធិកមហាវិទ្យាល័យព្រះសុរាម្រិតមក គណៈកម្មាធិការនាយក នៃស.ស.ខ បានចាត់គណៈប្រតិភូមួយ ដែលមានមិត្ត ថាច់ សេវណ្ណ, ឡុក វ៉ន នឹង លាង ហាប់អាន ជាសមាជិកនាំយកព្រះរូបសំណាកនៃសម្តេចព្រះបិតាសិក្សាធិការជាតិ ធ្វើពីម្នាងសិលា ទៅប្រគេនព្រះគ្រូនាយកនៃមហាវិទ្យាល័យ ។

★

បន្ទាប់ពីបានស្តាប់សេចក្តីថ្លែងការណ៍នៃព្រះរាជរដ្ឋាភិបាលពីថ្ងៃ ៣១ កក្កដា ១៩៦៣ តាមវិទ្យុជាតិមក គណៈកម្មាធិការនាយក បានមូលមតិគ្នាផ្ញើញត្តិមួយច្បាប់ថ្វាយចំពោះសម្តេចឪ ដើម្បីនឹងវែកញែកផែនការបរហស្សប្រាយ នៃ មហាអំណាចលោកសេរីចំពោះប្រទេសយើង នឹងដើម្បីទបគួរព្រះអង្គនឹងនយោបាយព្រះអង្គ ( សូមអានអត្ថបទនៃញត្តិទី ១ ) ។

★

គណៈកម្មាធិការនាយក របស់យើង បានផ្ញើញត្តិមួយច្បាប់ថ្វាយព្រះបិតាសាមគ្គីភាពជាតិ ដើម្បីនឹងរាយកំចាយនូវឧបាយកលក្បត់ជាតិរបស់ចលនា «ខ្មែរសេរី» នឹង សារី - ថាន់

ហើយបញ្ជាក់នូវភក្ដីភាពរបស់ ស.ស.ខ ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះអង្គ និង នយោបាយព្រះអង្គ ក្រោយដែលបានស្ដាប់ព្រះរាជសន្និសិទ ដែលវិទ្យុជាតិបានផ្សាយ ពីថ្ងៃ ៣០-១០-១៩៦៣ (សូមអានអត្ថបទនៃញត្តិទី ២) ។

★

ដើម្បីនឹងគាំទ្រនូវសេចក្ដីសំរេចចិត្តនៃសមាជពិសេស អំពីជាតូបនីយកម្មនៃអាហារណ៍ និហារណ៍ ធនាគារ ការធានារ៉ាប់រង និងសុរាគារ ហើយនឹងការ "ផាត់" ជំនួយអាមេរិកសព្វបែបយ៉ាងចោល (ទាំងខាងយោធា ទាំងខាងសេដ្ឋកិច្ច និង វប្បធម៌) គណៈកម្មាធិការនាយក បានផ្ញើញត្តិមួយច្បាប់ថ្វាយព្រះបិតាសេដ្ឋកិច្ចជាតិ កាលពីថ្ងៃ ២១ វិច្ឆិកា ១៩៦៣ (សេចក្ដីនេះនៅក្នុងញត្តិទី ៣) ។

★

គណៈកម្មាធិការនាយក បានធ្វើសេចក្ដីថ្លែងតបមួយច្បាប់ ដើម្បីនឹងបដិសេធនូវការអួតអាងផ្សេងៗ របស់ចលនាខ្មែរសេរី ហើយនឹងការប្រមាថមើលងាយចំពោះសម្ដេចឪយើង ។ សេចក្ដីបដិសេធទាំងនោះ មានចុះទាំងស្រុង នៅក្នុងទស្សនាវដ្ដីយើងលេខនេះស្រាប់ ។

★

NOUVELLE REVUE PÉDAGOGIQUE (bimensuel)
Fernand Nathan et Cie,
18, Rue Monsieur le Prince, Paris 6e

L'ECOLE DES PARENTS (mensuel)
47, Rue de Miromesnil, Paris 8e

L'ECOLE LIBÉRATRICE (bihebdomadaire)
94, rue de l'Université, Paris 7e

ពរសព្ទសាធុការ

# នៃសមាគមសាស្ត្រាចារ្យខ្មែរ

ថ្វាយបំពោះសម្តេចព្រះប្រមុខរដ្ឋ

ក្នុងឱកាសបពិធីចំរើនព្រះជន្មគំរប់ ៤២ ព្រះវស្សា

នៅឱកាសប្រកបដោយនក្ខត្តប្ញក្សនៃពិធីចំរើនព្រះជន្មព្រះអង្គ គំរប់ ៤២ វស្សានេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ជាសមាជិកនៃគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ តំណាងសាស្ត្រាចារ្យជាងប្រាំបីរយនាក់ជាសមាជិក,

សូមព្រះរាជទានឱកាសប្រសិទ្ធទូវពរសព្ទសាធុការ ដ៏វិសេសវិសាលថ្ងៃថ្លាអនេកអនន្ត ថ្វាយចំពោះព្រះអង្គ សូមព្រះអង្គមានព្រះជន្មយឺនយូរពាប់រយព្រះវស្សា ហើយទ្រង់ស្ថិតនៅតែក្នុងព្រះសុខុមាលភាពដ៏ប្រណិតប្រកបដោយព្រះសុខភាពដ៏បរិបូណ៌ ដើម្បីបានជាម្លប់ដ៏ត្រជាក់ត្រជុំគ្រប់គ្រងកូនចៅព្រះអង្គទាំងប្រាំមួយលាននាក់ ឲ្យបានឋិតថេរនៅលើកោះសន្តិភាពនេះ ព្រមទាំងជាព្រះអគ្គមគ្គុទ្ទេសក៍បណ្តុះបណ្តាលសម្បូរណភាពនៅលើកោះនោះផង ។

ព្រះអង្គគឺពិតជាស្ថាបនិកដ៏ឈ្លាសវៃនឹងក្លៀវក្លា ប្រកបដោយព្រះគតិបណ្ឌិត ជាហេតុដែលនាំឲ្យព្រះអង្គទ្រង់ប្រមូលបានទូវលក្ខណសម្បត្តិគ្រប់បែបយ៉ាង ដើម្បីនឹងបំពេញព្រះកិច្ចដ៏លំបាកនេះ ពោលគឺកិច្ចការការពារកោះសន្តិភាពនឹងថ្នែកោះនេះឯង ។

បំពោះការឃោសនាទីង សកម្មភាពវិទ្ធង្សនារបស់ពួក "ខ្មែរសេរី" ដែលមាន សម - សារី នឹង សឺង - ង៉ុកថាន់ ជាមេ នឹងរបស់ពួកមហាអំណាចជាចៅហ្វាយ

គេទាំងក្នុងទាំងក្រៅប្រទេសវិញ ដែលមានគោលបំណងយ៉ាងជាក់ច្បាស់ ទីនវាយរំលំនយោបាយឯករាជ្យ អព្យាក្រឹត្យ សន្តិភាព របស់ព្រះអង្គទីន ប្រជាជាតិខ្មែរនោះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយជឿជាក់ថា ពលរដ្ឋនៃកោះសន្តិភាពអាស្រ័យដោយព្រះកិច្ចណែនាំដ៏ក្ងស្វាងនៃព្រះអគ្គមគ្គុទ្ទេសករបស់ខ្លួន ប្រាកដជាវាយកំទេចឲ្យវិនាសសាបសូន្យបានជាមិនខាន ហើយចេះតែមានល្បឿនទៅមុខទៀតជានិច្ច ។

ទូលព្រះបង្គំទាំងឡាយ សូមបួងសួងជាថ្មីម្ដងទៀត ដល់ទេវតាសព្វលោកធាតុ មានទេវតារក្សាស្វេតច្ឆត្រជាដើម សូមជួយផ្សះព្រះរោគាព្យាធិរបស់ព្រះអង្គឲ្យយ៉ាងធុតធាប់ សូមជួយចំរើនព្រះជន្មព្រះអង្គឲ្យបានយឺនយូរ រាប់រយព្រះវស្សា ហើយសូមរក្សាការពារព្រះអង្គជាដរាបតរៀងទៅ ។

ទូលព្រះបង្គំទាំងឡាយ សូមសំដែងនូវភក្តីភាពដ៏បរិសុទ្ធរបស់ខ្លួនចំពោះព្រះអង្គទីន នយោបាយព្រះអង្គ ហើយសូមប្ដេជ្ញាដើរតាមព្រះអង្គ ទីននយោបាយនេះ លុះដល់ទីអវសាន ។

ក្រាបបង្គំទូលថ្វាយ

ភ្នំពេញ, នៅថ្ងៃទី ២៧ តុលា ១៩៦៣

សូមព្រះបង្គំទាំងឡាយជាសមាជិក

នៃគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

▣

សូមអានឲ្យចប់ ហើយឲ្យយោបល់ផង!

ញត្តិទី ១

### សូមព្រះតេជៈគុណលើត្បូង

## សូមក្រាបបង្គំទូលថ្វាយសម្តេចព្រះប្រមុខរដ្ឋ

### សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ

ដោយបានស្តាប់សេចក្តីថ្លែងការណ៍នៃព្រះរាជរដ្ឋាភិបាលតាមវិទ្យុជាតិ កាលពីថ្ងៃទី ៣១ កក្កដា ១៩៦៣ ;

ដោយបានសង្កេតឃើញ តាមសេចក្តីថ្លែងការណ៍នេះ ថាមហាអំណាចខ្លះដែលចេះតែនិយាយមាត់ក្រៅថា ខ្លួនគេសុខចិត្តទទួលស្គាល់អព្យាក្រឹតភាពខ្មែរ ហើយព្រមយកប្រជាជាតិខ្មែរធ្វើជាមិត្ត ប៉ុន្តែតាមពិត ពួកគេកំពុងតែឧបត្ថម្ភបរិវារគេ ឲ្យសំរេចនូវផែនការវាយសម្លាប់អព្យាក្រឹតភាពនិងប្រជាជាតិខ្មែរជារៀងរាល់ថ្ងៃ ;

ដោយយល់ឃើញថា ផែនការដែលប្រទេសជាបរិវារគេរៀបចំលុកលុយប្រទេសខ្មែរបានលេចរូបរាងកាន់តែច្បាស់ឡើងៗហើយ ដូចជារាជការថៃបានចាត់ក្នាក់ងារខ្លួននិងពួក "ខ្មែរសេរី" ឲ្យដើរធ្វើទ្ធង់ទ្រនា ដើម្បីនឹងបញ្ចូលខេត្តកោះកុងទៅក្នុងក្រញាំនៃទុរជនទៅបាងកក ; ដូចជារដ្ឋការវៀតណាមខាងត្បូងបានបញ្ជាឲ្យកងទ័ពរបស់ខ្លួនបើកបរយន្តហោះក៏មាន កប៉ាល់ទឹកក៏មាន រថក្រោះក៏មាន ចូលមករំលោភលើអធិបតេយ្យភាពខ្មែរ ហើយបាញ់សម្លាប់ ឬ បំផ្លាញប្រជាពលរដ្ឋខ្មែរ ដើម្បីបង្កើតនូវសំអប់នឹងគំនុំរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ ហើយដើម្បីនឹងបង្កសង្គ្រាមរាតត្បាតរបស់គេ ;

ដោយយល់ឃើញថា អំពើទាំងប៉ុន្មាននោះ គឺពិតជាការចាប់ផ្តើមនៃផែនការដែលពួកមិត្តក្លែងក្លាយរបស់យើងនឹងបរិវារគេរៀបចំជាយូរមកហើយ ហើយចាំតែឱកាសល្អ នឹងវាយប្រទេសខ្មែរ ;

ដោយយល់ឃើញថា ពាក្យត្មះតិះដៀលទាំងប៉ុន្មានដែលមេដឹកនាំថៃ និង វៀតណាមខាងត្បូង ហើយនិង សារពត៌មានចៅហ្វាយគេពោលចំពោះប្រទេសខ្មែរនិងសម្តេចឪ សុទ្ធតែជាពាក្យភូតភរ មួលបង្កាច់ សំដៅទៅបំបែកបំបាក់ប្រជាករខ្មែរពីព្រះអគ្គមគ្គុទេសក៍របស់ខ្លួន ហើយថាពាក្យទាំងនេះ សុទ្ធតែចូលក្នុងផែនការវិទ្ធង្សនានិងវាយប្រទេសខ្មែរ;

ដោយយល់ឃើញថា អាវុធដ៏សក្តិសិទ្ធិរបស់ប្រជាជាតិខ្មែរក្នុងគ្រាដ៏អាសន្ននេះ គឺមានតែសាមគ្គីជាតិមួយប៉ុណ្ណោះ សមដូចសម្តេចឪតែងតែទ្រង់មានព្រះបន្ទូល;

ដោយយល់ឃើញថា ដរាបណាប្រជាជាតិខ្មែរយើងនៅតែប្រុងប្រយ័ត្នចំពោះផែនការបំបែកបំបាក់និងរុករានរបស់សត្រូវដែលប្រើរូបភាពគ្រប់បែបយ៉ាង ហើយនៅតែរៀបជួរយ៉ាងណែនពីក្រោយព្រះអង្គសម្តេចឪ ដរាបនោះជ័យជំនះច្បាស់ជាស្ថិតនៅខាងខ្មែរជានិច្ច;

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ជាមាជិកនៃគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមថ្លែងនូវសេចក្តីក្តៅក្រហាយយ៉ាងមហិមារបស់ខ្លួន ចំពោះរដ្ឋការវៀតណាមខាងត្បូង និងរាជការថៃ ព្រមទាំងចៅហ្វាយរបស់គេដែលបានរៀបចំវាយជនជាតិខ្មែរ;

មានសេចក្តីឈឺចាប់យ៉ាងក្រៃលែង ហើយសូមបដិសេធយ៉ាងដាច់អហំការនូវពាក្យត្មះតិះដៀលនិងការប្រមាទកាតពានទាំងប៉ុន្មាន ដោយមួលបង្កាច់ចំពោះសម្តេចឪ និងចំពោះប្រជាជាតិខ្មែរ;

សូមសំដែងជាថ្មីម្តងទៀតនូវភក្តីភាពរបស់ខ្លួនចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះអគ្គ-មគ្គុទ្ទេសក៍ជាតិ និង ចំពោះមាគ៌ានយោបាយអព្យាក្រឹត និង បង្រួបបង្រួមជាតិរបស់ព្រះអង្គ

ហើយសូមបេក្ខជាជាថ្មីម្តងទៀត នឹង ដង្ហែសម្តេចឪតាមមាគ៌ាអព្យាក្រឹត នឹងបង្រួបបង្រួមជាតិនេះ លុះត្រាតែបានសម្រេចជាអវសាន ។

សូមក្រាបបង្គំទូលថ្វាយ

ភ្នំពេញនៅថ្ងៃទី ៣ សីហា ១៩៦៣

ទូលព្រះបង្គំទាំងឡាយ ជាសមាជិកនៃគណៈកម្មាធិការនាយក

នៃសមាគមសាស្ត្រាចារ្យខ្មែរ

★

ដំ – បណ្ណាគារ ប៊ុត នាង លេខ ១៧៦ វិថីខេមរភូមិន្ទ ភ្នំពេញ

– បណ្ណាគារ ហុង យូ លេខ ៤ វិថីចន្ទរាជា, ភ្នំពេញ

ណឹ – បណ្ណាគារ ដួង ដូណារ៍ លេខ ២២២ វិថីខេមរភូមិន្ទ, ភ្នំពេញ

ង – បណ្ណាគារភ្នំពេញ លេខ ៥៩ វិថីប៉ាស្ទ័រ ភ្នំពេញ

អ – បណ្ណាគារសុភមិត្រ លេខ ៣៦៧ C ផ្លូវកម្ពុជាក្រោម ភ្នំពេញ

នឹងមានសេចក្តីរីករាយនឹងបញ្ចុះថ្លៃ ១០ % ដល់បណ្តាមិត្ត

ន្ក – សាស្ត្រាចារ្យយើង ដែលទៅទិញសៀវភៅសិក្សា នៅបណ្ណាគារ ទាំងនេះ ហើយដែលបានបង្ហាញប័ណ្ណសមាជិកសមាគមយើងផង ។ ម្យ៉ាងទៀត បើមិត្តត្រូវការបញ្ជាទិញសៀវភៅអ្វី តិចឬច្រើនទៅ

ក្រោះ – ប្រទេសបារាំង មិត្តក៏អាចនឹងទិញតាមរយៈបណ្ណាគារ ហុង យូ បានដែរ ។

ញត្តិទី ២

សូមព្រះតេជៈដឹកលើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយសម្តេចព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ

បន្ទាប់ពីបានស្តាប់ព្រះរាជសន្និសិទរបស់ព្រះអង្គ វែកញែកប្រាប់ប្រជាជាតិអំពីខ្មាយកលដ៏លាមករបស់ពួក "ខ្មែរសេរី" ដែលមាន សឺង-ង៉ុកថាន់ នឹង សម-សារី ជាមេ ហើយដែលវិទ្យុជាតិបានយកមកផ្សាយកាលពីថ្ងៃល្ងាចទី ៣ តុលា ១៩៦៣ នេះមក

ទូលព្រះបង្គំទាំងឡាយជាសមាជិកនៃគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ តំណាងសាស្ត្រាចារ្យចំនួនជាងប្រាំបីរយនាក់ជាសមាជិក ក្នុងព្រះរាជអាណាចក្រទាំងមូល មានសេចក្តីឈឺចាប់ក្តៅក្រហាយឥតឧបមាចំពោះសេចក្តីឃោសនារបស់ពួកវាដែលសុទ្ធតែជាពាក្យភូតភរ មួលបង្កាច់ដែលគ្មានខ្មែរឯណាក្រៅពីគ្នាវាពីរបីនាក់នោះជឿឡើយ ។

ព្រោះតាមពិត ពលរដ្ឋខ្មែររូបណាក៏បានដឹង បានស្គាល់ បានឃើញរួចអស់ហើយនូវអកម្មភាពពីអតីតកាល នឹងបច្ចុប្បន្នកាលរបស់ សឺង-ង៉ុកថាន់ នឹង សម-សារី ហើយនឹងពួកវាដែលគ្រាន់តែជាផលិតផល នឹង ជាអាយ៉ងរបស់មេក្លោងលោកសេរីតែប៉ុណ្ណោះគត់ ។

ព្រោះតាមពិត គោលបំណងរបស់ សឺង-ង៉ុកថាន់ សម-សារី នឹងពួកវាគឺដូចជាគោលបំណងរបស់ សារិត ថាណារ៉ាត ង៉ោ ឌិនយៀម ហើយនឹងគោលបំណងរបស់ចៅហ្វាយពួកទាំងនេះតែប៉ុណ្ណោះ គឺប៉ងគាស់រំលំអព្យាក្រឹតភាពខ្មែរ បំផ្លាញបូរណភាពជាតិ ដើម្បីនឹងបញ្ចូលប្រទេសខ្មែរឲ្យទៅជាបរិវារសេអាតូតែប៉ុណ្ណោះ ។

ព្រោះតាមពិត សកម្មភាពទាំងប៉ុន្មានរបស់ សឺង-ង៉ុកថាន់ សម-សារី នឹង ពួកវាទាំងខាងក្រៅ ទាំងខាងក្នុងប្រទេសខ្មែរ សុទ្ធតែសំដៅទៅបំបែកបំបាក់សាមគ្គីភាព

នៃពលរដ្ឋខ្មែរពីអង្គសម្តេចឪដែលជានិមិត្តរូបនៃកម្លាំងជាតិ សុទ្ធតែសំដៅទៅបំបែកបំបាក់ខ្មែរ ហើយឃោសនាបន្ទុំថា ពួកវាជា " អ្នកកសាងជាតិមិនមែនធ្វើវិទ្ធង្សនា " ទៅវិញ ។

សរុបសេចក្តីទៅ សកម្មភាពទាំងប៉ុន្មានរបស់ សឺង - ង៉ុកថាន់ សម - សារី និង ពួកវាទាំងខាងក្នុង ទាំងខាងក្រៅ គឺសំដៅរៀបចំការវាយប្រហារប្រទេសខ្មែរតែម្យ៉ាងប៉ុណ្ណោះ ។

ប៉ុន្តែដោយមានជំនឿយ៉ាងច្បាស់ទៅលើព្រះបញ្ញាញាណដ៏ឈ្លាសវៃនៃអង្គសម្តេចឪ ទាំងមានជំនឿយ៉ាងច្បាស់ទៅលើការភ្ញាក់រលឹកស្មារតីសម្បជញ្ញៈរបស់ជនរួមជាតិ យើងតាំងមូលដែលតែងតែប្រុងប្រយ័ត្នជានិច្ចចំពោះសកម្មភាពទាំងឡាយរបស់ សឺង- ង៉ុកថាន់ សម - សារី និងពួកវាទាំងខាងក្នុង ទាំងខាងក្រៅប្រទេសនោះ

ទូលព្រះបង្គំទាំងឡាយជាសាស្ត្រាចារ្យខ្មែរជឿជាក់ថា ឧបាយកលដ៏លាមករបស់ពួកខ្មែរដែលតាំងខ្លួនឯងថា " សេរី " នោះ ច្បាស់ជាត្រូវវិនាសសាបសូន្យជាមិនខាន

ហើយទូលព្រះបង្គំទាំងឡាយ សូមសំដែងជាថ្មីម្តងទៀតនូវស្វាមីភក្តិ និងភក្តីភាពចំពោះព្រះអង្គសម្តេចឪ និង នយោបាយព្រះអង្គ សូមប្តេជ្ញាជាដាច់អហំការថា នឹងមិនទទួលស្គាល់វរជនឯណាក្រៅពីព្រះអង្គ ហើយសូមប្តេជ្ញាដង្ហែតាមព្រះអង្គលុះដល់អវសាន ។

សូមក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ៦ តុលា ១៩៦៣

ទូលព្រះបង្គំទាំងឡាយជាសមាជិកនៃគណៈកម្មាធិការនាយក
នៃសមាគមសាស្ត្រាចារ្យខ្មែរ

★

សូមមិត្ត ជួយផ្តល់អត្ថបទដល់ទស្សនាវដ្តីយើងផង!

## ញត្តិទី ៣

សូមព្រះតេជៈដំកល់លើត្បូង

សូមក្រាបបង្គំទូលថ្វាយសម្ដេចព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ

ដោយបានស្ដាប់សេចក្ដីថ្លែងការណ៍ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យសំរេចអំពីជាតូបនីយកម្មនូវផ្នែកសំខាន់ៗ នៃសេដ្ឋកិច្ចជាតិ ពោលគឺអាហរណ៍និហរណ៍ ធនាគារ ការធានារ៉ាប់រងហើយនឹងសុរាគារ ក្នុងពេលថ្មីៗនេះ ហើយនឹងសេចក្ដីប្រកាសជាឯកច្ឆន្ទលែងទទួលជំនួយយោធា សេដ្ឋកិច្ច បច្ចេកទេស នឹងវប្បធម៌របស់អាមេរិក ក្នុងសមាជពិសេសកាល ពីថ្ងៃទី ១៩ វិច្ឆិកា ១៩៦៣ នេះ

ទូលព្រះបង្គំទាំងឡាយជាសមាជិកនៃគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរតំណាងសាស្ត្រាចារ្យជាងប្រាំបីរយនាក់ជាសមាជិក មានបីតិរីករាយឥតឧបមា ហើយសូមសំដែងថ្វាយព្រះអង្គនូវកតញ្ញូធម៌ដ៏ជ្រាលជ្រៅជាថ្មីទៀត ព្រមទាំងសូមប្ដេជ្ញាការពារព្រះរាជវិធានការថ្មីនេះដោយអស់សមត្ថភាព ព្រោះថាគោលការណ៍សេដ្ឋកិច្ចហើយនឹងគោលការណ៍លែងទទួលជំនួយបរទេសដែលហូរចេញមកពីព្រះរាជបញ្ញាញាណដ៏មុតធ្លុះនេះ មិនមែនគ្រាន់តែប្រែសភាពសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏បានប្រែសភាពនយោបាយ នឹងសង្គមកិច្ចក្នុងប្រទេសទៀតផង ។

ក្នុងផ្នែកសេដ្ឋកិច្ច ព្រះរាជមាគ៌ាថ្មីនេះក៏មានទំហំស្មើនឹងព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យក្នុងឆ្នាំ ១៩៥៣ ដូចនោះដែរ គឺថាចាប់ពីពេលនេះតទៅ រាជរដ្ឋាភិបាលបានយកកូនសោ

សេដ្ឋកិច្ច - ហិរញ្ញវត្ថុមកកាន់កាប់ផ្ទាល់តែម្តង ជាហេតុនាំឲ្យសេដ្ឋកិច្ចជាតិដែលជាបេះដូងនៃប្រជាជាតិនោះមានដំណើរលូតលាស់ទៅមុខ ស្របតាមសេចក្តីប៉ងប្រាថ្នារបស់ប្រជាពលរដ្ឋទាំងមូល ហើយលែងអាស្រ័យតាមតែឆន្ទៈរបស់ពួកមូលធននិយមផ្តាច់មុខ ដែលធ្លាប់តែធ្វើក្បៀនធ្វើផ្គរដាក់ពលរដ្ឋតូចតាច ស្រេចតែអំពើចិត្តឬស្វាគៈលាភលន់របស់វាទៀតហើយ ។ មិនតែប៉ុណ្ណោះ រូបិយប័ណ្ណក៏បានទទួលការត្រួតត្រាយ៉ាងហ្មត់ចត់ ហើយជំងឺខុទភាពក៏បានរកថ្នាំឃើញហើយ ។

ជាងនេះទៅទៀត វិធានការជាតូបនីយកម្មអាចធ្វើឲ្យប្រជាជាតិយើងរៀនរស់នៅដោយថ្លៃថ្នូរ ដោយគ្មានជំនួយប្រកបដោយលក្ខខណ្ឌរបស់បរទេស ជាពិសេសគឺជំនួយអសុទ្ធចិត្តរបស់អាមេរិក ដែលសមាជពិសេសបានប្រកាសសំរេចឈប់ទទួលទៀតហើយ ព្រោះជំនួយមានបំណង មានលក្ខខណ្ឌទោះជាខាងសេដ្ឋកិច្ចក្តី ខាងយោធាក្តី ខាងវប្បធម៌ក្តី សុទ្ធតែបង្កើតជាអាសន្នអន្តរាយដល់នយោបាយសន្តិភាព អព្យាក្រឹតរបស់យើងៗ ដូចនេះ ព្រះរាជមាគ៌ាដ៏ក្លាហានខាងសេដ្ឋកិច្ចនេះ ជាវិភាគទានមួយធំសំបើមដល់ការពង្រឹងនិងការធានាអះអាងដល់សេរីភាពនយោបាយជាតិយើងខាងក្នុងប្រទេស ក៏ដូចជាពង្រឹងកិត្យានុភាពយើងលើឆាកអន្តរជាតិដូច្នោះដែរ ។

មិនតែប៉ុណ្ណោះ ព្រះមាគ៌ាថ្មីៗនេះ បានជះនូវអានុភាពមួយយ៉ាងសក្តិសិទ្ធិទៅលើការសង្គ្រោះជីវភាពរបស់រាស្ត្រតូចតាច ដោយផ្តល់សារៈសំខាន់ដល់ផលិតផលជាតិឲ្យសមរម្យ ដោយជួយទិញផលិតផលពីផលិតករឲ្យបានថ្លៃ ហើយលក់ផលិតផលបរទេសឲ្យបានយ៉ាងថោកបំផុត ដោយមិនបាច់ឆ្លងតាមពួកអ្នកឈ្មួញកណ្តាលឡើយ ។ តាមមាគ៌ានេះប្រជាជីវភាពមុខជានឹងឡើងយ៉ាងរហ័ស មិនមែន "មួយម៉ោង ១០ គីឡូ" ដូចមុនទៀតឡើយ ។ ចំពោះចិត្តគំនិតនិងអំពើមិនស្អាតស្អំ ដែលតែងតែមានពីដើមរៀងមកក្នុងចំណោមភ្នាក់ងាររាជការ បើងវិញ វិធានការថ្មីនេះក៏បានជាឧសថមួយសំខាន់ដែរ ពីព្រោះបានបន្ថយនូវឱកាសសំរាប់ប្រព្រឹត្តអំពើអាក្រក់ទាំងនោះ ។

សរុបសេចក្ដីទៅ ព្រះរាជវិធានការថ្មីពីរដ៏សំខាន់នេះ គឺជាតូបនីយកម្មនូវផ្នែកសំខាន់ៗនៃសេដ្ឋកិច្ចជាតិ និងការលែងទទួលជំនួយយោធា សេដ្ឋកិច្ច បច្ចេកទេស និងវប្បធម៌របស់អាមេរិកនេះបានពង្រឹងនូវមូលដ្ឋាននៃនយោបាយសន្តិភាព អព្យាក្រឹតកាន់តែខ្លាំងថែមទៀត បាននាំឲ្យសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិឲ្យស្គាល់នូវសភាពមួយថ្មី បានលើកស្ទួយប្រជាជីវភាពមួយកំរិតថ្មីទៀត បានធ្វើឲ្យប្រជាជាតិទាំងមូលភ្ញាក់រលឹកនូវសម្បជញ្ញៈជាតិ ហើយផ្សព្វផ្សាយនូវកិត្យានុភាពកម្ពុជាទៅក្នុងឆាកអន្តរជាតិទៀតផង ។

ប៉ុន្តែ វិធានការជាអាយុជីវិតដែលបានធ្វើឲ្យប្រជាជាតិទាំងមូលមានសេចក្ដីរីករាយជាអនេកនេះ ត្រឡប់ជាបានទទួលការខឹងសំបារយ៉ាងឃោរឃៅពីសំណាក់ចក្រ-ពត្តិលោកសេរី នាយទុនផ្ដាច់មុខនិងមន្ត្រីវៀចវេរចង់ក្បត់ខ្លះទៀតវិញ ពីព្រោះវិធានការនេះបានធ្វើឲ្យខូចផែនការយុទ្ធសាស្ត្ររបស់ចក្រពត្តិក្នុងអាស៊ីភាគអាគ្នេយ៍ ហើយធ្វើឲ្យខូចរបររកស៊ីជញ្ជក់ឈាមរាស្ត្រខ្មែរ ដែលនាយទុនផ្ដាច់មុខ និងមន្ត្រីក្រខ្វក់ខ្លះធ្លាប់តែប្រព្រឹត្តតាមក្បាលចិត្តជាដរាបរៀងមកហើយ ។ ដូចនេះ សត្រូវជាតិទាំងបីពួកខាងលើនេះ មុខតែរកបង្កើតឧបាយកលនិងរហស្សូបាយគ្រប់បែបយ៉ាង ដើម្បីជាឧបសគ្គដល់វិធានការនេះ ។

ក្នុងករណីនេះ ទូលព្រះបង្គំទាំងឡាយជាសមាជិកនៃគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ សូមប្ដេជ្ញាដង្ហែតាមសម្ដេចឪ ដើម្បីពុះពារនូវឧបសគ្គគ្រប់បែបយ៉ាងក្នុងការដឹកនាំវិធានការដ៏ប្រសើរលើសលុបទាំងពីរយ៉ាងនេះ ឲ្យបានសំរេចនូវជោគជ័យជាអវសាន ។

ក្រាបបង្គំទូលថ្វាយ ភ្នំពេញនៅថ្ងៃទី ២១ វិច្ឆិកា ១៩៦៣

ទូលព្រះបង្គំទាំងឡាយ

ជាសមាជិកនៃគណៈកម្មាធិការនាយក

នៃសមាគមសាស្ត្រាចារ្យខ្មែរ

# សេចក្ដីឆ្លើយតបរបស់សមាគមសាស្ត្រាចារ្យខ្មែរ

## ចំពោះការផ្សាយវិទ្យុរបស់ចលនា "ខ្មែរសេរី"

យើងសឹងតែមិនចាំបាច់ខាតពេលនឹងឆ្លើយតបចំពោះពាក្យសំដីអប្រិយរបស់ពួកឯងនេះ ដែលជាអាយ៉ងបរទេសផងទេ ។ ប៉ុន្តែ បានជាយើងអត់ទ្រាំមិនបាននឹងជះការពិតឲ្យចំកណ្ដាលមុខពួកឯងដូច្នេះ គឺដើម្បីនឹងប្រាប់ពួកឯងឲ្យភ្ញាក់ខ្លួន អំពីមតិជាឯកច្ឆន្ទរបស់ប្រជាជាតិខ្មែរដ៏ពិតៗ នៅឯខាងមាតុភូមិឯណោះ ហើយដើម្បីនឹងប្រាប់ឲ្យឯង ឲ្យពួកគ្នាឯងទាំងក្នុងទាំងក្រៅស្រុកទាំងប៉ុន្មាន នឹងចៅហ្វាយ "សេរី" របស់ឯង ដឹងខ្លួនឲ្យច្បាស់ទៅថា នយោបាយនិងយុទ្ធសាស្ត្រនៃ "ចលនាខ្មែរសេរី" ដែលជាស៊ុតឬជាផលិតផលរបស់លោក "សេរី" នោះ មិនអាចនឹងដឹកនាំឯង ពួកគ្នាឯងនឹងចៅហ្វាយរបស់ឯងឲ្យទៅដល់ទីបញ្ចប់ឯណាមួយក្រៅអំពីបរាជ័យនោះឡើយ ។

សព្វថ្ងៃនេះ ក្រោយពីបានទទួលវិទ្យុ ៣ គ្រឿងយ៉ាងខ្លាំងៗពីម្ចាស់ឯងមក ពួកឯងនេះបានធ្វើប្រតិបត្តិការវាយខ្ទប់ប្រទេសជាតិរបស់ឯង ដោយរួមផ្សំសម្របសម្រួលបទភ្លេងជាមួយនឹង "កាប៉ូរ៉ាល" ឯងគឺ សារិត នឹង យៀម ។ ក្នុងការប្រតិបត្តិវគ្គទី ១ នៃវិទ្ធង្សនាលើរលកធាតុអាកាស គឺវគ្គវាយបំបែកសាមគ្គីភាពពលរដ្ឋខ្មែរពីអង្គសម្ដេច នឹងបំបែកសាមគ្គីជាតិខ្មែរនេះ ពួកឯងសង្ឃឹមថានឹងអាចឈានចូលទៅដល់វគ្គទី ២ ក្នុងពេលឆាប់ៗនេះទៀត គឺវគ្គវាយប្រហារផ្ទប់ពីក្រៅ នឹង បំផ្លាញពីក្នុងរបស់ឯង ។ ប៉ុន្តែ ចំពោះផែនការដ៏ឧក្រិដ្ឋនេះ យើងគ្រាន់តែព្រមានឯងថា វាមិនអាចនឹងក្លាយទៅជាការពិតបានទេ ប៉ុន្តែវានៅត្រឹមតែជាការរវើរវាយរបស់ជនក្បត់ជាតិ ជនលោភអំណាច លោភទ្រព្យធនពោលគឺពួកឯងដែលរត់ទៅដេកយល់សប្ដិនៅក្នុងទ្រុងចៅហ្វាយបរទេសរបស់ឯងតែប៉ុណ្ណឹងទេ ។

ឯងចូលណាស់ទៅឬ? ហេតុអ្វីក៏យើងថាការឃោសនារបស់ពួកឯងទឹងក្រុមហ៊ុនឯងមិនអាចទឹងសំរេចបំណងបាន? ការឃោសនារបស់ឯង សារី - ថាន់ ត្រូវតែបរាជ័យ ពីព្រោះយើងជាពលរដ្ឋខ្មែរ យើងមិនជឿ! យើងមិនជឿមកពីយើងធ្លាប់ស្គាល់ធាតុរបស់ឯងអស់ទៅហើយ ។ តើធាតុរបស់ឯងនេះជាអ្វីទៅ?

ថាន់! អី, ឯងប្រដូចខ្លួនឯង ទៅនឹង de Gaulle ផង? ហើយប្រដូច "ចលនាខ្មែរសេរី" ទៅនឹងចលនារំដោះជាតិ? នែ! ករទេ ហើយការនេះ ទាំងខ្លួនឯងក៏បានដឹងស្រាប់ហើយ ។ តាមការពិតឯងនេះដូចជា Tchang Kai-Tchek ឯនោះទេ, Tchang Kai-Tchek ដែលជាជនប្រតិកិរិយាផុតលេខ ហើយដែលត្រូវប្រជាជនចិនដ៏ខ្លាំងមហិមាដេញឲ្យមកជ្រកនឹងកម្ពោត Taïwan ឯនោះ ។ សព្វថ្ងៃនេះ Tchang Kai-Tchek ដែលជាសហភាគីរបស់ឯងកំពុងតែស៊ីដុល្លាបន្តកំឡាំង ហើយចំកោងខ្លួនស្រែកប្រៀនតាមបង្គាក់រំពាត់របស់ចៅហ្វាយវា តាមវិទ្យុរបស់ចៅហ្វាយវា ព្រមទាំងបញ្ចូលអ្នកវិទ្ធង្សនាទៅក្នុងមាតុភូមិប្រជាមានិតុ ហើយដស្រោយក្តែង១ ថា: "រំដោះប្រទេសចិន! រំដោះប្រទេសចិន!" ឯងមើលមើល តើ Tchang Kai-Tchek ដូចថាន់ឯង ឬមិនដូច? ឯងស្តាប់មើលតើប្រជាជនចិនជឿវា ឬ មួយក៏គេភ្ញុតទឹងវា? អើ ថាន់ឯងហ្នឹងក៏អញ្ចឹងដែរ! គឺ ថាន់ឯងជាជនលក់ប្រទេសហើយ "ចលនាខ្មែរសេរី" ជាចលនាហ្វាស៊ីស្ត ប្រតិកិរិយាជាកម្លាំងរបស់មេក្លោងលោកសេរី ដែលខ្មែរបានស្គាល់រួចអស់ទៅហើយនោះ ។

សារី! ឯងហ៊ានយកខ្លួនឯងទៅប្រដូចនឹង Fidel Castro ផង? អត់ទេ! វាខុសគ្នាដូចជាថ្ងៃនឹងយប់អញ្ចឹង ។ សារីឯងនេះ បើតាមចរិត តាមគំនិត ទឹង តាមការរស់នៅរបស់ឯង ឯងនេះជាBatista ។ Batista ក្រោយដែលបានផ្តាច់ការសង្កត់សង្កិនប្រជាជនអស់មួយរយៈពេលមក បានត្រូវប្រជាជនគុយបាដេញផាស់ក្រញាំទៅលាក់ខ្លួនពួនអាត្មាឯទ្រុងក្បែរៗនោះ ហើយបង្កបង្កើតជាចលនាមួយ ដូចចលនាសារីឯងអ៊ីចឹងដែរ ជាក់

ស្លាកថា “ចលនាជនគុយបាភៀសខ្លួន” ។ មួយថ្ងៃៗ Batista នឹងក្រុមហ៊ុនវាគិតតែពីស្រែកពីស្រុកជិតខាងមក ដើម្បីបំបែកបំបាក់សាមគ្គីជាតិ ហើយគ្នាវាដែលនៅខាងក្នុងគិតតែបំផ្លាញ ។ ពួកនេះ បានទទួលការឧបត្ថម្ភពីចៅហ្វាយរបស់វាដល់ចិត្តហើយ ព្រោះវានៅទីងប្រមុះចៅហ្វាយវា ។ ប៉ុន្តែ ឯងមើលមើល៍ ជនគុយបាជឿវាទេ ? អត់ទេ! មានម្តងនោះពួក Batista អាយ៉ងលោកសេរីដែលជា “គុយបាសេរី” ក្រោយពីបានបំបែកបំបាក់តាមរលកធាតុអាកាសហើយ ពួកវាក៏បានចូលវាយលុកមាតុភូមិគុយបា ។ ប៉ុន្តែពួកគូលីសេរីទាំងនោះ បានត្រូវប្រជាជនគុយបាវាយកំទេចយ៉ាងស្អាតតែក្នុងរយៈប៉ុន្មានម៉ោងប៉ុណ្ណោះ ។

អើ! វាសនារបស់ឯងវាមុខតែដូចវាសនា Batista ជាគ្រូកនឯងដូចនេះហើយ ។

សារុបសេចក្តីទៅ ពួកឯងនេះ ថាន់ នឹង សារី សុទ្ធតែជាជនជាប់កិច្ចសន្យាថានឹងសុខចិត្តប្រើឧបាយកលសព្វបែបសព្វយ៉ាង មានការលក់ប្រទេសជាតិឯងជាដើម ដើម្បីនឹងបំរើផលប្រយោជន៍របស់ចក្រពត្រ “លោកសេរី” ជាម្ចាស់ពួកឯង ហើយសព្វថ្ងៃនេះឯងបានបង្ហាញកស្តុតាងយ៉ាងច្បាស់ថា ពួកឯងកំពុងតែឋិតនៅក្នុងទ្រុងជាមួយគ្នានឹងង៉ោ-ឌិនយៀម, សារិត ថាណាពត, ជាង កាយ ចេក, យ៉ាងប្រត្យក្ស ។ ឯចលនាដែលពួកឯងបង្កក់ឲ្យឈ្មោះថា “ខ្មែរសេរី” នោះ វាគ្រាន់តែជាក្រុមហ៊ុនមួយនៃជនលក់ជាតិ ដែលមានបំណងស្របគ្នាត្រង់ស្រែកឃ្លានអំណាចផ្តាច់ការ យសសក្តិ ទ្រព្យសម្បត្តិ ហើយដែលចាំតែទទួលបញ្ជាអនុវត្តផែនការឧក្រិដ្ឋ ដែលចៅហ្វាយលោកសេរីរបស់ឯងបង្គាប់មកតែម្យ៉ាងប៉ុណ្ណោះ ។ បំណែកឯបក្ខពន្ធរបស់ឯងទាំងក្រៅទាំងក្នុងប្រទេសវិញ វាជាដៃជើងវិទ្ធង្សនារបស់ឯងក្នុងការបំបែកបំបាក់សាមគ្គីរវាងយុវជន រវាងពលរដ្ឋ នឹង អង្គសម្តេចឪ ហើយនឹងបំផ្លិចបំផ្លាញ មានការបំផ្លាញស្ថានីយវិទ្យុជាជំនួយចិនប្រជាមានិតនៅស្ទឹងមានជ័យជាភស្តុតាងស្រាប់ ។

យើងជាពលរដ្ឋខ្មែរ យើងមិនជឿពួកឯងមកពីយើងបានស្គាល់ឧបាយកលរបស់ពួកឯងរួចអស់ហើយ ។ ពីមុនសារីបានបង្កើតអង្គការកាសែតមួយប្រជាធិបតេយ្យ ថាដើម្បីប្រមូលអ្នកស្នេហាសិទ្ធិសេរីភាព តែការពិតគឺដើម្បីប្រមូលជនទាំងឡាយណាដែលមានគំនិតហ្វាស៊ីស្តដូចឯងវិញនោះ ។ ពីមុន ថាន់បានចោលពាក្យថា ការដែលឯងចេញទៅក្រៅនេះ គឺដោយមានការព្រមព្រៀងជាមួយ នឹង សម្ដេចឪហើយ ។ តែលុះល្បិចនេះត្រូវបែកធ្លាយទៅ ឯងថា ឯងសព្វថ្ងៃនេះកំពុងតែ "រំដោះ" ប្រទេសកម្ពុជា ។ លុះឥឡូវគេដឹងថាឯងកំពុងតែ "រំដោះ" ប្រទេសអព្យាក្រឹតរបស់ឯង បញ្ចូលទៅក្នុងសៃវៀនព្រៃនគរ បាត់កកហើយ ឯងក៏ថាសព្វថ្ងៃនេះឯងកំពុងតែ "រំដោះ" កម្ពុជាក្រោមទៅវិញ ។ ហ៊ឺស! រំដោះកម្ពុជាក្រោមផង? រ៉ាមិនដែល! ឯងជាខ្ញុំកញ្ជះង៉ោឌិនយៀមនឹងកញ្ជះមេក្មាងលោកសេរី តើធ្វើម្ដេចនឹងហ៊ានរំដោះពីចៅហ្វាយឯងដូចពាក្យដែលឯងថានោះបាន? អើ! បើថាសព្វថ្ងៃនេះ ឯងកំពុងតែអនុវត្តផែនការវាយកំទេចជនស្នេហាជាតិនៅក្នុងកម្ពុជាក្រោមនោះបានជាពិត ៗ មែនទេ?

សង្ខេបសេចក្ដីទៅ កុំថាឡើយបើតែឯងប្រើស្ថានីយវិទ្យុ ដើម្បីនឹងធ្វើវិទ្ធង្សនាលក់ជាតិឯង ទោះបីមេក្មាង "លោកសេរី" ផ្ដល់ស្ថានីយវិទ្យុឲ្យឯងដល់ទៅ ៣០ គ្រឿងទៀត ក៏លទ្ធផលរបស់ក្រុមហ៊ុនឯងមិនឡើងទៅណាឆ្ងាយពីសូន្យដែរ ពីព្រោះពលរដ្ឋខ្មែរសម្ដេចឪ ភ្លឺស្វាងណាស់ មិនមែនដូចកាលសម័យដែលឯងនាំទៅធ្វើកញ្ជះបក្រុពត្រូជប៉ុននោះទេ ។ ពីព្រោះអ្នកណាក៏ស្គាល់ឧបាយកលរបស់ឯងអស់ហើយ គឺ ឃោសនាពីខាងក្រៅដើម្បីបង្អាប់ព្រះកិត្តិយសសម្ដេចឪ ដើម្បីបំបែកយុវជន បញ្ញវន្ត នឹងពលរដ្ឋខ្មែរពីព្រះអង្គសម្ដេចឪ ។ លុះបំបែកបំបាក់សាមគ្គីជាតិរួចហើយ ពួកឯងនឹងដៃជើងឯងទាំងក្នុងទាំងក្រៅ ក៏ចាប់វាយប្រហារប្រទេសជាតិឯងតែម្ដង ហើយឯងក៏បានឡើងធ្វើជាហ៊ីត្លែរខ្មែរនៅពេលនោះ ។

ប៉ុន្តែ នេះគ្រាន់តែជាការយល់សប្តិរបស់ឯងទេ ។ ទោះជាថ្ងៃណាក៏ដោយ សេចក្តីសង្ឃឹមរបស់ឯង ក៏មិនអាច នឹងក្លាយទៅជាការពិតបានឡើយ ពីព្រោះពលរដ្ឋខ្មែរបានឈរតំរៀបជួរគ្នាយ៉ាងណែនណាន់តាន់តាប់ជុំវិញព្រះអង្គសម្តេចឪ ហើយបានប្តេជ្ញាជាស្រេចថានឹងការពារព្រះអង្គ ការពារនយោបាយព្រះអង្គ នឹងការពារទឹកដីជាទីស្នេហារបស់ខ្លួន ទោះបីខ្លួនត្រូវបំពេញពលិកម្មដ៏ធំបែបណាក៏ដោយ ។

“ក្ហើយ! ថ្កុព្រះ ក៏បេះតែព្រះទៅចុះ ចំណែកឯប្រទេសជាតិ បេះតែទៅមុខជាដរាប” ។

## TEXTES ET DOCUMENTS

N° 3

## L'ANTISÉMITISME

L'Égypte, la Grèce et les Juifs.
L'antisémitisme chrétien.
Les Juifs asservis.
L'attitude des Pâpes.
Le Ghette.
Vers l'émancipation.
La Révolution Française.
L'affaire Dreyfus.
Les Nazis.
Persécutions nazies en Erance.
La déportation des enfants.
Les Chambres à gaz,
Les grands écrivains face à l'antisémitisme.
Le sionisme.
Pour une solution des problèmes.

Nombreux textes

Prix : 2,50 F (Franco : 2,70)

20% de réduction pour toute commande de plus de 20 exemplaires
En vente dans les centres régionanx de documentation pédagogique.
au S. E. V. E. N. 13, rue du Four - Paris (6°)
et auprès des correspondants des « Cahiers Pédagogiques »

(សេចក្តីឆ្លើយតបនេះ បានធ្វើឡើង នៅក្រោយពេលដែល “វិទ្យុព្រៃ” បានឃោសនាភូតករថា សារី-ថាន់ រត់ចូលព្រៃ គឺ “ដើម្បីនឹងធ្វើការរំដោះប្រទេសជាតិដូចជាលោក de Gaulle”) ។

✶

## ស្ថានភាពខាងហិរញ្ញវត្ថុ

សមាគមបានទទួលត ៗ មកទៀត ពី៖

| | | | |
|---|---|---|---|
| វិទ្យាល័យ សន្តិភាព ( កំពង់ស្ពឺ ) | 9\|12\|63 | 440 | រៀល |
| អនុវិទ្យាល័យ ស្គួន | 17\|12\|63 | 1870 | – |
| – ព្រៃកពោធិ | 29 12\|63 | 1120 | – |
| – បាត់ដំបង? | | | |

| | | | |
|---|---|---|---|
| វិទ្យាល័យ សន្តិភាព ( កំពង់ស្ពឺ ) | 9\|12\|63 | 440 | រៀល |
| អនុវិទ្យាល័យ ស្គួន | 17\|12\|63 | 1870 | – |
| – ព្រៃកពោធិ | 29 12\|63 | 1120 | – |
| – បច្ចេកទេស | ,, | 1000 | – |
| វិទ្យាល័យ ព្រះសីហនុ | ,, | 1200 | – |
| – ខ្មែរ-អង់គ្លេស | 24\|12\|63 | 860 | – |
| – សន្តិភាព | ,, | 900 | – |
| អនុវិទ្យាល័យ ពាមជីកង | ,, | 1020 | – |
| វិទ្យាល័យ ព្រះស៊ីសុវត្ថិ | ,, | 1480 | – |
| – បូករួម | | 9890 | – |
| – ចំណាយក្នុងរយៈពេលដដែលនេះ មាន៖ | | 5893 | – |
| – សំណល់ | | 3997 | – |
| – ប្រាក់ក្នុងបេឡាទាំងអស់ | | | |

95 086 ៛ + 3997 ៛ = 99 083 រៀល

ប្រាក់ទាំងអស់នេះបានយកទៅដាក់ទុកក្នុង «ធនាគារ» ខ្មែរដូចពីដើមរៀងមក ។ ក្រោយពីមានព្រឹត្តិការណ៍ មិនស្រួល អគ្គហិរញ្ញិកបានទៅសុំដកមករក្សាទុកម្តងរួចទៅ ហើយតែដោយធនាគារនេះមានជំហររឹងប៉ឹងគួរឲ្យទុកចិត្ត ព្រោះរាជការបានសំរេចទទួលកាន់កាប់បន្តពីឯកជនមក អគ្គហិរញ្ញិកក៏បានយកទៅផ្ញើទុកវិញ ។

សូមមិត្តសមាជិកទាំងអស់ជ្រាបថា ក្នុងឱកាសកែវមួយគ្រាដែលទើបនឹងចូលផុតទៅនេះ ពុំមានហេតុការណ៍អ្វីមួយមកប៉ះពាល់ដល់ហិរញ្ញវត្ថុនៃសមាគមយើង គួរជាទីបារម្ភឡើយ ។ សូមមិត្ត តំណាងទាំងអស់ជ្រាបម្យ៉ាងទៀត អំពីប្រាក់ភាគទានថា ក្រោយពីអគ្គហិរញ្ញិក បានទទួលចុះក្នុងបញ្ជីហើយ សុទ្ធតែមានធ្វើយតបវិញភ្លាម ឬហោចណាស់ក៏មានចុះក្នុងទស្សនាវដ្ដី ឬព្រឹត្តិបត្រយើងដែរ ។ ហេតុនេះ ប្រសិនបើមិត្តគ្មានឃើញចុះទេ នោះគឺច្បាស់ជាគ្មានបញ្ចូលក្នុងបេឡាទេ សូមមិត្តតំណាងរួសរាន់ជួយដេញដោលសួរ ដល់អគ្គហិរញ្ញិកឲ្យទាន់ពេលវេលាផង ។

អរគុណ

◙

## សម្ភារៈវិទ្យាសាស្ត្រ

នៅគ្រឹះស្ថាន ខាវ អ៊ិនហោ ( ភ្នំពេញ ) មានលក់សម្ភារៈបង្រៀន ខាងវិទ្យាសាស្ត្រធម្មជាតិ ដូចជាក្បាលមនុស្ស ភ្នែក សរីរាង្គបុរស ស្ត្រី សត្វសេះ និងបាណកជាតិផ្សេង ៗ ធ្វើអំពីជ័រ plastique ដែលអាចដោះផ្ដឹង សាប់ សួត ពោះវៀនចេញពីគ្នា និងផ្គុំវិញបាន ( តម្លៃពី ៣០០ ទៅ ៦០០រ ) ។

ខាងវិទ្យាសាស្ត្ររូបវិទ្យាមានម៉ាស៊ីនយន្តហោះ ម៉ាស៊ីនរថយន្ត ដែលធ្វើឲ្យដើរយ៉ាត ៗ បាន ហើយមានទំហំធំល្មមឲ្យកូនសិស្សមួយថ្នាក់ ៗ ពិនិត្យឃើញទាំងអស់គ្នា ( តម្លៃពី ១០០០ ទៅ ១៨០០រ ) ។



# ទស្សនសាស្ត្រ និង កវេទ្យ

ឱ យុវជន!

ឌុច រ័ត

ពាក់អាវបើកទ្រូងឡេវចំហរ បញ្ចេញខ្សែកទីងសាច់ដុំ
សក់ក្បាលពត់ពេនខ្ពស់ដូចក្អំ សាយជំទីកអប់ឡប់ប្រេបពី ។
ស្បែកជើងវៀវស្រួចដូចបន្លា ខាងលើវ៉ែនតាខោសង់ក្លី
ខ្សែដៃកំពាក់ដូចនារី ពេញទីសែនស្រស់កម្លោះថ្មី ។
ភ្នែកផ្ទាបភ្នែងស្ដាំមិនទីងទឹ ញាក់ញ៉ីរទេះទ្រេតបើឃើញស្រី
ហួចហុចដើមទ្រូងធ្វើវាហី ជូនហឹតបារីហុយផ្សែងទ្រុប ។
សព្វថ្ងៃពេលមានបុណ្យម្ដង ៗ នាំគ្នាត្រសងដើរផុលផុប
ជ្រកជ្រៀតជ្រួលជ្រើមទាំងថ្ងៃយប់ ពេលពន់ព្រលប់ដើរតាមស្រី ។
សម្ដែងទឹកមុខកាចសាហាវ ប៉ះប៉ុនវាយប្រាវគ្មានប្រណី
តែហ៊ានផ្ទងមុខ មុខហុយដី វាយបង្អួតស្រីដែលខ្លួនស្នេហ៍ ។
ខ្ញុំលើករឿងនេះមកពិនិត្យ ដោយមានគំនិតគិតនាំណែ
មិត្តអ្នកអប់រំដូចខ្ញុំដែរ ឲ្យជួយកុនកែខ្មែរក្មេងផង ។

★

# យើងនាំគ្នាធ្វើការ

ទំនុកច្រៀងដោយ

សង្វាក់រាំវង់តាមបទ «ឱផ្កាវំដួលនេះអើយ»

ឆុច រិង

យើងជាសាស្ត្រាចារ្យ
ប្រឹងធ្វើការដោយចិត្តខ្មីឃ្មាត

យើងចាំដោយស្នេហាជាតិ (ផ្ទួន)

ជួយញាតិឲ្យបានចំរើន
ចូរខិតខំរៀនដើម្បីស្ដារជាតិ

ជាតិជួយស្ទួយញាតិ (ផ្ទួន)

យើងសាងជាតិខ្មែរ ៗ

កាលបើយើងចាំហើយ
ឧមិត្តអើយយើងរីករាយដែរ

រីករាយដោយឃើញកូនដែរ (ផ្ទួន)

ចេះស្នេហ៍សច្ចយុត្តិធម៌
កូនខ្មែរបានល្អដោយលោកគ្រូខ្មែរ

ខ្មែរជួយជាតិខ្មែរ (ផ្ទួន)

ស្រុកខ្មែរចំរើនថ្កាន ៗ

◙


ទស្សនាវដ្ដី គួរអាន :

★ ទស្សនាវដ្ដី គ្រូបង្រៀន ចេញរាល់ទ្វេមាស

★ ទស្សនាវដ្ដី មិត្តសាលាបាលី ចេញរាល់ត្រីមាស




# អក្សរសាស្ត្រ
# ប្រភពរឿងកាកី

ឡុច - ដែង
សាស្ត្រាចារ្យ វិទ្យាល័យព្រះស៊ីសុវត្ថិ

ខ្ញុំបានអានសេចក្ដីអធិប្បាយអំពីប្រភពរឿង "កាកី" ក្នុងសៀវភៅ "អក្សរសិល្ប ប្រវត្តិសៀម" របស់លោក "ប្លឿង" សាស្ត្រាចារ្យពិសេស ទទួលការៈបង្រៀនភាសាសៀម នឹង អក្សរសិល្បវិជ្ជាសៀម នៅសកលវិទ្យាល័យ «ចូឡាលង្ករណ៍» និពន្ធក្នុង ព. ស. ២៤៩៥ តាំងពីដើមឆ្នាំ ១៩៦០ម៉្លេះ ។

ហេតុដែលខ្ញុំមិនបង់ចុះផ្សាយ ពីព្រោះខ្ញុំផ្អាក់ចាំទទួលការពិសោធន៍ខាងការបង្រៀនរឿងកាកីខ្មែរ ឲ្យបានយូរបន្តិចសិន ។ ឥឡូវនេះដល់ឆ្នាំទី ៣ នៃការបង្រៀនរឿងនេះហើយ ។ ដោយបានសិក្សាប្រៀបធៀបនូវអត្ថបទរឿងក្នុងភាសាទាំងពីរទៅ ខ្ញុំឃើញថារឿងមានសំរស់លំអម្យ៉ាងម្នាក់ ។

ខ្ញុំសូមលើកយកចំណុចមួយមកប្រដូចគ្នាមើល ចំណុះនោះគឺវត្ថុបំណងរបស់កវីក្នុងការនិពន្ធន៍រឿង ។ កវីសៀមមានបំណងចង់ទុករឿងកាកីនេះជាជំបូន្មានសំរាប់ទូន្មាន "ឥស្ត្រី" ក្នុងព្រះរាជវង្សានុវង្ស ចំណែកឯព្រះរាជកវីខ្មែរ ព្រះអង្គចង់ទូន្មាន "ស្ត្រី" ទាំងឡាយមិនចំពោះ ។ ដូច្នេះ យើងឃើញថា ទស្សនៈរបស់ព្រះរាជកវីខ្មែរ ដូចជាទូលំទូលាយជាង ។

យើងដឹងស្រាប់ហើយថា "រឿងកាកី" ជាស្នាដៃមួយដ៏ឆ្នើមក្នុងអក្សរសិល្បខ្មែរ ព្រះរាជនិពន្ធឡើងដោយព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គ "ឌួង" ព្រះបរមកោដ្ឋ ។

ព្រះបាទសម្ដេចព្រះអង្គ "ឌួង" ជារាជឱរសអង្គទី ៥ នៃព្រះបាទសម្ដេចព្រះអង្គ "អេង" ។ ព្រះអង្គទ្រង់ប្រសូត នៅ ព. ស. ២៣៣៩ គ. ស. ១៧៩៦ ។ ព្រះអង្គឡើងសោយរាជ្យនៅ គ. ស. ១៨៤១ ហើយទ្រង់ទទួលប្រាប្ដាភិសេកនៅក្រុងឧដុង្គ ក្នុង ព. ស ២៣៩០ គ. ស. ១៨៤៣ ។ ទ្រង់សោយទីវង្គតនៅថ្ងៃសុក្រ ៥ កើត ខែកត្ដិក ឆ្នាំវកតោស័ក ព. ស ២៤០៣ ត្រូវនឹងថ្ងៃទី ១៩ ខែតុលា គ. ស. ១៨៦០ ក្នុងព្រះជន្មាយុ ៦៤ ព្រះវស្សា ។

ព្រះរាជជីវប្រវត្តិ ទីង កិច្ចការស្នាព្រះហស្ថរបស់ព្រះអង្គ មានអធិប្បាយដោយពិស្ដារក្នុងពង្សាវតារ នៃប្រទេសកម្ពុជាស្រាប់ទៅហើយ យើងមិនចាំបាច់លើកយកមករៀបរាប់ក្នុងទីនេះទៀតទេ ។

ព. ស. ២៣៥៨ គ. ស. ១៨១៥ ជាសកករាជ ដែល "រឿងកាកី" នេះ ត្រូវបាននិពន្ធឡើង ក្នុងយុវវ័យរបស់ព្រះអង្គ ( ១៩ ព្រះវស្សា ) មុនឡើងគ្រងរាជ្យ ។

ឥឡូវនេះ យើងនឹងភ្ជាប់ "រឿងកាកី" នេះទៅនឹងការស្រាវជ្រាវរករប្រភពដើមនៃរឿង ។

## ប្រភពដើមនៃរឿង

ព្រះបាទអង្គ "ឌួង" ទ្រង់បានបញ្ចប់ "រឿងកាកី" ដោយប្រយោគនេះ ៖

"ដំណើរខាងកាកី ប្រែសេចក្ដីសៀមភាសា
ជាពាក្យខ្មែរកាព្យ សូមចប់រឿងម៉្មះហោង" ។

ពិតមែនតែមានសេចក្ដីថា ព្រះអង្គបានប្រែរឿងនេះចេញពីភាសាសៀមក៏ដោយ ក៏ព្រះអង្គបានកែប្រែគ្រឿងតែងពាក្យពេចន៍ ដំណើររឿង ឲ្យស្រុបទៅតាមចិត្ត គំនិត វប្បធម៌

សង្គមធម៌របស់ខ្មែរសុទ្ធសាធ ហើយកវីសៀមនេះទៀតក៏ពុំមែននិពន្ធរឿងនេះឡើងដោយបិត្តគំនិតផ្ទាល់ខ្លួននោះឡើយ ។ គេបានផ្តិតចម្លង "រឿងកាកី" នេះចេញមកពីរឿងក្នុងនិបាតជាតកពីររឿង គឺ ៖

ក – រឿង "កាកាតិជាតក" ៖ ក្នុងជាតកនេះ នាង "កាកី" មានឈ្មោះហៅថា "កាកាតិ" ចំណែកឯគន្ធព្វ គេឲ្យឈ្មោះថា "នាដកុវេរ" ។ "កាកាតិជាតក" នេះមានដំណើររឿងខ្លី ចប់ត្រង់ស្តេចគ្រុឌនាំនាង "កាកាតិ" មកប្រគល់ថ្វាយព្រះបាទព្រហ្មទត្តវិញប៉ុណ្ណោះ ។

ខ – រឿង "កុណាលជាតក" ជាជាតកមួយទៀត ដែលមានដំណើររឿងដូចគ្នា នឹង "កាកាតិជាតក" ខុសគ្នាតែត្រង់កន្លែងដែលនាងកាកីនោះ មានឈ្មោះថា "កាកដន្តិ" ទៅវិញ ។

រឿងជាតកទាំងពីរខាងលើនេះ កំពុងស្ថិតនៅក្នុងការស្រាវជ្រាវរកឯកសារជាភាសាខ្មែរតទៅទៀត ។

អាស្រ័យហេតុនេះ គប្បីយើងធ្វើសេចក្តីសង្កេតថា ច្បាប់ដើមនៃរឿងជាភាសាបាលី បន្ទាប់ទៅពញាព្រះឃ្លាំង "ហុន" បានរៀបរៀងមកជាភាសាសៀម ហើយចុងក្រោយបង្អស់ ជាភាសាខ្មែរដោយព្រះបាទអង្គ "ឌួង" ។ តាមសេចក្តីនេះ ព្រះបាទអង្គ "ឌួង" បានបញ្ជាក់កស្តុតាងក្នុងព្រះរាជាម្តុកជា ជាពាក្យពេចន៍ពីរប្រយោគដាច់ពីគ្នាថា ៖

..."ចរចាកបុរី បុរាណវេណី មកស្ថិតនៅនា ស្រុកទេពនគរ កុលករចិន្តា **តែងតាមបទធា ឲ្យ**លោកសំដែង ។"...

..."ពាក្យពោលពុំពី ពេះពេបនៃនិ – **ធានតាមបទធា ឲ្យលោក ដើមអាទិ** ផ្សែតជាតិប្រាជ្ញា ចេះចងសាសនា ពុំសូវគួរសម ។"...

តាមសម្មតិកម្ម ព្រះបាទអង្គឌួង "ប្រាកដ" ជាបានទត បានអានអត្ថបទដើមជាភាសាបាលីពុំខាន ។

តទៅទៀតនេះ យើងនឹងលើកយកសេចក្ដីផ្ដើមក្នុងភាសាទាំងពីរ ដែលជាលក្ខណៈគោលសំខាន់បណ្ដាលឲ្យកវីនិពន្ធ "រឿង" កាកី នេះឡើង មកប្រៀបប្រដូចគ្នាមើល ។ បើយើងប្រែតាមពាក្យពេចន៍មួយម៉ាត់ ៗ ដោយមិនគិតដល់វិធីចាប់ចុងចួនក្នុងកំណាព្យ ពាក្យប្រារព្ធជាភាសាសៀមនោះ នឹងបានសេចក្ដីដូចតទៅនេះ៖

"សូមសំដែងថែងនិទានក្នុងកាលមុន កាលគ្រាអង្គទ្រង់សិលជិនវរ ត្រាប់សញ្ជរប៉ងប្រយោជន៍ពោធិញ្ញាណ ស្វោយព្រះជាតិជាសកុណាពញាសត្វ បានដករឿងជាតកមកបរិហារ ប្រយោជន៍សំដែងថែងពិតចិត្តស្រីពាល ឲ្យប្រុសជាញដឹងដើងកាឡត្រី" ។

បន្ទាប់មក សូមអានសេចក្ដីជាខ្មែរក្នុងព្រះពជារម្ភកថា វិញ៖

"ដំណើរដំណាល ស្រីស្រស់ពុតពាល ចិត្តដូសាមាន្យ ធុកាឲ្យស្ដីលោកីមិញមាន ចិត្តប្រុងប្រាសប្រាណ ប្រាសប្រែអនិច្ចា" ។

ក្នុងរឿងកាកីសៀមជាពាក្យកាព្យ យើងគប្បីសង្កេតពិចារណា តាមវគ្គទាំង ៣ ដូចតទៅនេះ៖

ក) វគ្គទី ១ – ចាប់តាំងពីដើមរឿងរហូតទៅដល់កន្លែងដែលស្ដេចគ្រុឌ វិលត្រឡប់មកលេងបាស្កាជាមួយនឹងស្ដេចព្រហ្មទត្តម្ដងទៀត ក្រោយដែលបានលួចនាងកាកីទៅហើយ ។

បំពោះវគ្គនេះ មានអ្នកខ្លះឲ្យយោបល់ថាពុំមែនជាសំនួនវោហារ របស់ចៅពញាព្រះឃ្លាំង "ហុន" ឡើយ គឺប៉ុន្តែប្រហែលជារបស់ព្រះមហាយសភ អ្នកនិពន្ធរឿង "ពាលីប្រដៅប្អូន" ទៅវិញ ។

ខ) វគ្គទី ២ តែងជាបទមហោរី ចាប់តាំងពីគន្ធនដេញពិណផ្ចាញ់ផ្ចាលស្ដេចគ្រុឌ រហូតទាល់តែដល់កន្លែងនាងកាកីត្រូវបណ្ដែតពោងពាយ ។ វគ្គនេះប្រាកដជាស្នាដៃរបស់ចៅពញាព្រះឃ្លាំង "ហុន" មែន ។

គ) វគ្គទី ៣ – វគ្គនេះបរិយាយតទៅទៀត អំពីនាងកាកីរសាត់តាមពោងពាយ ទៅជួបនឹងនាយសំពៅកណ្ដាលសមុទ្រ ខូចខ្លួនខូចប្រាណជាមួយនឹងនាយសំពៅ រហូតពីនាយសំពៅធ្លាក់ទៅដៃចោរ ហើយនៅទីបំផុតបានទៅជាមហេសីរបស់ព្រះបាទទសវង្ស ស្ដេចដែលសោយរាជ្យនៅនគរអភ័យសាលី ។ និយាយពីរឿងរ៉ាវទៅនៅនគរពារាណសីវិញ ដល់ព្រះបាទព្រហ្មទត្តទ្រង់សោយទិវង្គតទៅ ពួកសេនាមាត្យសព្វមុខមន្ត្រីតូចធំ ក៏មូលមតិគ្នាលើកនាយកុវេរគន្ធព្វជាស្ដេចសោយរាជ្យស្នង ។ កាលបើដឹងថានាងកាកីនៅមានជីវិតរស់នៅឡើយនៅនគរអភ័យសាលី គន្ធព្វក៏លើកទ័ពទៅវាយដណ្ដើមយកនាងមកវិញបាន ហើយអភិសេកនាងកាកីឡើងជាអគ្គមហេសី ។

កវីដែលនិពន្ធវគ្គទី ៣ បន្ថែមជាថ្មីនេះ មានឈ្មោះហៅថា "ជោតិ" នាមត្រកូល "មណីរ័ត្ន" ។ ពាក្យពេចន៍សំនួរវោហារក្នុងវគ្គបន្ថែមនេះ មានសុភាពទន់ភ្លន់ជាងវគ្គទី ១ នឹងវគ្គទី ២ ឆ្ងាយណាស់ ។ បានជានិពន្ធថែមថ្មី ក៏ព្រោះតែកវីនេះយល់ថា រឿងកាកីនេះហាក់ដូចជាមិនទាន់ចប់សព្វគ្រប់ គេចង់ធ្វើឲ្យនាងកាកីគប់ប្រសព្វនឹងឧបសគ្គនានាសិន រួចហើយបានមកសោយសុខតាមធម្មតាវិញ ។

ខ្ញុំសូមជូនជីវប្រវត្តិរបស់ចៅពញាព្រះឃ្លាំង "ហុន" ទុកណាជាពុំមែនជាកវីខ្មែរក៏ដោយ តែជីវប្រវត្តិនេះអាចនឹងមានអត្ថប្រយោជន៍ទាក់ទងនឹងការសិក្សាអក្សរសិល្ប៍ខ្មែរយើងខ្លះជាពុំខាន ។

ជីវប្រវត្តិរបស់កវី.–

ចៅពញាព្រះឃ្លាំង "ហុន" ជាបុរសសំខាន់មួយនាក់ក្នុងសម័យក្រុងរតនកោសិន្ទ្រ (ក្រុងទេពព្រះនគរបវរបាងកកសព្វថ្ងៃនេះ) ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះពុទ្ធយ៉ត-ហ្វាចូឡាលោក (ប្រសូត ព.ស. ២ ២៧៩ គ្រងរាជ្យ ព.ស. ២.៣២៥, សោយទិវង្គត ព.ស. ២ ៣៥២) ។ ចៅពញាជាអ្នកចំបាំងផង ជាសេនាមាត្យជាន់ខ្ពស់ផង

ព្រមទាំងជាកវីឯកក្នុងព្រះរាជមន្ទីរផង ។ យើងដឹងដោយស្តួចស្តើងណាស់អំពីជីវប្រវត្តិ
របស់កវីនេះ ។ សៀវភៅលំដាប់នាមត្រកូល "ប៊ុងឡុង" បានបញ្ជាក់ថា លោក
ជាបុត្ររបស់ចៅពញាបតិន្ទ្រសុរិន្ទ្រពុទ្ធជ័យ "ប៊ុត-ម៉ី" នឹងលោកស្រី "បំរើន" ។

ដំបូងលោកមានយសសក្តិជាហ្លួង សរវិជិត នាយដានស្រុកទទ័យ ។ ក្នុងពេល
ចលាចលនៅក្រុងធនបុរី ហ្លួងវិជិត នាយប៊ុនណាក បានម៉ៃឡា នឹងពញាសគ៌ បាននាំ
គ្នាលើកបក្សពួកចូលមកឡោមព័ទ្ធព្រះរាជវាំង ។ កាលបើសម្ដេចព្រះចៅក្រុងធនបុរី
( តាក-ស្រិន ) ទ្រង់ចុះពាក់ទឹងលះបង់រាជ្យចេញសាងព្រះផ្នួសនៅវត្តអរុណរាជវរារាម
ហើយ ហ្លួងវិជិតនឹងបក្សពួកក៏បាននៅថែរក្សានគរ ។ ក៏ប៉ុន្តែ ដល់ក្រោយមក ពួក
អ្នកចូលមកកាន់កាប់អំណាចថ្មីនេះ មានយោបល់ទាស់ទែងខ្វែងគំនិតវិវាទប្រឆាំងគ្នាឯងឡើង ។
ខណៈនោះ សម្រេចព្រះពុទ្ធយ៉តហ្វាចូឡាលោក ( កាលនៅជាសម្ដេចពញាមហាក្សត្រិយ៍
សឹកនៅឡើយ ) កំពុងលើកទ័ពមកវាយប្រទេសខ្មែរ ។ ដល់ព្រះអង្គទ្រង់ជ្រាបហេតុ
ការណ៍ចលាចលនៅក្រុងធនបុរីបែបនេះភ្លាម ទ្រង់ក៏ប្រញាប់ប្រញាល់លើកទ័ពត្រឡប់
មកវិញ កាត់តាមស្រុកប្រាចីនបុរី ( បសុ៊មបុរី ) ។ ហ្លួងសរវិជិតបានចេញទៅទទួល
ព្រះអង្គនៅវាល "សែនសែប" ក្រាបថ្វាយទូវព័ត៌មានសំខាន់ៗ ទាំងអស់ហើយបាន
ក្រាបទូលអញ្ជើញព្រះអង្គនាំទ័ពចូលព្រះនគរ ។

ដល់សម្ដេចព្រះពុទ្ធយ៉តហ្វាឡើងសោយរាជ្យ ព្រះអង្គក៏បានតែងតាំងហ្លួងសរវិជិត
ជា "ពញាពិពត្ស្យនកោសា" តមកក៏បានដំឡើងតំណែងជា "ពញាព្រះឃ្លាំង"។ លោក
បានបំរើកិច្ចរាជការរហូតទាល់តែទទួលអនិច្ចកម្មនៅ ព.ស ២.៣៤៨ គ.ស. ១.៨០៥ ។

លោកបានទុកស្នាដៃអក្សរសិល្បដូចតទៅ ៖

- លិលិតស្រីវិជ័យ ជាតក

- លិលិតពេជ្រមកុដ

- លិលិតព្យុហយាត្រាពេជ្រភួង

- ឥណាវ

- មហាជាតកបទរាយវែង បំពោះតែកុមារកណ្ហ និង មទ្រីកណ្ហ

- បទមហោរី រឿងកាកី

លោកបានអនុគ្រោះប្រែរឿងសាមកុក និងបាននិពន្ធរឿងរាជាធិរាជ ដោយកិច្ចសហប្រតិបត្តិការ ជាមួយពញាឥន្ទ្រអគ្គរាជ, ព្រះភិរម្យរស្មី និង ព្រះស្រីភូរិប្រីជា ។

សេចក្តីសង្កេត .–

១– សម្តេចព្រះពុទ្ធយ៉តហ្វាចូឡាលោក បានរៀបអភិសេកព្រះអង្គ " អេង " ដែលជាព្រះរាជបិតារបស់ព្រះបាទអង្គ " ឌួង " ឡើងសោយរាជ្យជាសម្តេចព្រះនារាយណ៍រាមាធិបតី អម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ( គ. ស ១៧៧៩ - ១៧៩៦ ) ។

២– លិលិត ៖ សៀមសំដៅដល់អត្ថបទដែលគេនិពន្ធឡើងដោយផ្សំកំណាព្យ និងពាក្យរាយឲ្យតរណ្តំគ្នា ។

៣ – បទរាយវែង ៖ សៀមសំដៅដល់បទដែលប្រើក្នុងរឿងមហាជាតក៍ ហើយខ្មែរយើងហៅថា "បទកំរងកែវ" ទៅវិញ ។ បំពោះបទកំរងកែវនេះ សៀមសំដៅដល់ពាក្យពេចន៍ឃ្លាប្រយោគសរសេរតាមធម្មតា គ្មានការរណ្តំចាប់ចុងចួនគ្នាឡើយ ។

"ស្នាមហង្សតែងស្រង់ស្រះស្រី ហង្សអ្វីអប្រិយ មកផឹកឯទឹកថ្លុកល្អក់ ។

រូបល្អចិត្តក៏អាក្រក់ ស្អុយព្រៃលាមក ក្រអូបតែក្លិនអសារ ,, ។ ( កំហែងស្តេចគ្រុឌ )

# ការបង្កើតកូនចៅ នៃរុក្ខជាតិមានផ្កា

ម៉ម ណៃ

សាស្ត្រាចារ្យវិទ្យាសាស្ត្រធម្មជាតិ

វិទ្យាល័យ កំពង់ធំ

អស់មិត្តបានឃើញទីនផ្នែកអស់មិត្តហើយ នូវរុក្ខជាតិទាំងឡាយដែលបានបង្កើតកូន-ចៅ ៗ តែថាការបង្កើត កូន-ចៅនោះ ដូចគ្នានឹងមនុស្សសត្វក្នុងលោកិយនេះ ឬទេ ? ខ្ញុំពុំឆ្លើយថាដូច ឬ មិនដូចនោះទេ ខ្ញុំទុកឲ្យអស់មិត្តអារកាត់ទៅចុះ ហើយខ្ញុំគ្រាន់តែនិយាយអំពីការបង្កើតកូន-ចៅ នៃរុក្ខជាតិ ៗ ជាពិសេស ខ្ញុំនិយាយតែពីរុក្ខជាតិដែលមានផ្កា ៗ

ដើមឡើយ សូមអស់មិត្តជ្រាបអំពីផ្នែករបស់ផ្កាដោយត្រួសៗសិន ៗ បុប្ផាជាសរីរៈ (organe) មួយរបស់រុក្ខជាតិ ៗ វាមានផ្នែកដូចតទៅនេះ ៖

- ទង – ទងមាននាទីនឹង ភ្ជាប់តួបុប្ផាទៅនឹងមែកត្រង់សន្ទឹកតូចមួយ (bractée) ៗ ចុងទងម្ខាងទៀតប៉ោងកំពីង ហើយទីនោះជាលំនៅនៃផ្នែកផ្សេងៗ នៃបុប្ផា
- កញ្ចុំត្របកក្រៅ – កញ្ចុំនេះកើតបានដោយសារ ត្របកក្រៅច្រើននៅរួមគ្នា ៗ ត្របកក្រៅមានចំនួនតិច-ច្រើនទៅតាមបែបបុប្ផា ៗ ពល់តែត្របកក្រៅសុទ្ធតែបៃតងជានិច្ច ៗ
- កញ្ចុំត្របកក្នុង – ចំនួនត្របកក្នុង ក៏មិនខុសគ្នានឹងចំនួនត្របកក្រៅដែរនេះ មិនបានសេចក្ដីថាស្មើគ្នានោះទេ តែថាចំនួននោះវាប្រែប្រួលទៅតាមបែបផ្កាទៅវិញ ៗ ម្យ៉ាងទៀតត្របកក្នុងក៏ប្លែកពីត្របកក្រៅដែរ គឺត្របកក្នុងមានពណ៌ក្រហម, កុឡាប, លឿង, ស . . .

• កេសរ – កញ្ចុំទាំងពីរខាងនេះ បានឱបក្រសោបកេសរ (étamines) ។ រាល់តែកេសរសុទ្ធតែជាសរីរៈឈ្មោលរបស់រុក្ខជាតិ ។ លិង្គនេះមាន ៖

. ទងខ្លីតូចមួយ (filet)

. ស្បោងលំអងមួយ (anthère)

នៅក្នុងស្បោងនោះមានម្សៅល្អិតៗពោលគឺលំអងផ្កា (Pollen) ។ នៅគ្រប់តែលំអងផ្កា មានកោសិកាឈ្មោលមួយ (cellule mâle) ជានិច្ច ។

. ស្បូន – វាជាសរីរៈញី ( ឬមេ ) របស់រុក្ខជាតិលិង្គមេនេះ កើតឡើងដោយសារតែបោកញីច្រើនរួបរួមគ្នា ។ រាល់តែស្បូនតែងតែមាន ៖

. ពោះកំពីង គឺអណ្ឌាស័យ (ovaire)

នៅក្នុងអណ្ឌាស័យនោះមានពង ( គឺបុប្ផាណ្ឌ = ovule ) ។

. កមួយខ្លី ឬ វែង (stylet)

. ក្បាលមួយនៅលើ ក ( តាមមតិខ្ញុំ ខ្ញុំឲ្យឈ្មោះក្បាលនោះជា " តំរងលំអង " ដែរ )

លិង្គបុប្ផាទាំងពីរប្រភេទនេះ ជួនកាលមានទាំងពីរនៅក្នុងផ្កាតែមួយ ជួនកាលមានតែកេសរ ឬ ស្បូននៅក្នុងផ្កាមួយៗទីទៃពីគ្នា ។ បុប្ផាណាមានតែកេសរ បុប្ផានោះមាននាមថា " ផ្កាឈ្មោល " ។ ផ្ទុយទៅវិញ បុប្ផាណាមានតែស្បូន បុប្ផានោះឈ្មោះថា " ផ្កាមេ " ។ ជួនកាលគេឃើញផ្កាឈ្មោល និង ផ្កាញីនៅលើរុក្ខជាតិតែមួយដើម ជួនកាលវានៅលើដើមទីទៃពីគ្នា ។

អស់មិត្តទើបតែនឹងបានជ្រាបត្រួសៗអំពីផ្នែករបស់ផ្កាទេ ។ តែឥឡូវនេះអស់លោក នឹង ឈប់ត្រឹមនេះ ឬ យ៉ាងណា ? មើលទៅអស់មិត្តមុខជា នឹង បោះជំហានទៅមុខទៀតហើយ ។ កាលដែលអស់មិត្តលើកជើងឈានដើរ អស់មិត្តបានដើរចំកន្ទង់ " រួមដំណេក " របស់រុក្ខជាតិ ។ ពេលនេះអស់បានឃើញអ៊ីចឹងហើយ អស់មិត្តចាប់អារម្មណ៍ អស់មិត្តក៏ចាប់ពិនិត្យរឿងនេះដែរ ។

អស្ចារ្យណាស់ " ការរួមដំណេក " នេះ វាខុសពីការ ការប្រព្រឹត្តរបស់មនុស្សនឹងសត្វ ។ ព្រោះការរួមភេទនេះ វាអាចប្រព្រឹត្តទៅឯងៗ , ដោយសត្វល្អិត, ដោយទឹក, ដោយខ្យល់ក៏មាន ។

មែនហើយផ្កាក៏ សរីរៈផ្កាអាចបង្កើតកូនចៅបានដែរ ។ អាស្រ័យហេតុនេះ ស្បោងកេសររហែក លំអងផ្កាប្រុសចាកលំនៅ ។ វាធ្លាក់ចុះ វាហើរតាមខ្យល់ វាហោះហើរតាមសត្វល្អិត, វាហែលបណ្តោយទឹក ។ ដំណើរផ្សងព្រេងនេះធ្វើឲ្យលំអងស្ទើរតែទាំងអស់គ្មានភ័ពវាសនាផង ។ ក្នុងដំណើរដដែលនេះមានលំអងខ្លះ មានសំណាងដែរ គឺបានទៅទំនៅលើក្បាលស្បូន ( តំរងលំអង ) ។ នៅលើតំរងនោះលំអងត្រូវជាប់ដោយទឹកស្បូន ( ទឹកស្អិតៗ ) ។ បានទឹកស្បូនជាអាហារ លំអងក៏រីកធាត់ធំឡើង ហើយមានបុិចពន្លក ។

ពន្លករបស់លំអងមានសភាពវែងទៅៗ ជាបំពង់ ហើយកាន់តែជំរុលខ្លួនជ្រៅទៅៗ ទៅក្នុងស្បូន ។ កាលបើបំពង់លំអងទៅប៉ះនឹងបុប្ផាណ្ឌ ហើយចូលទៅក្នុងបុប្ផាណ្ឌទៀត ។ ពេលនោះកោសិកាឈ្មោល នឹងកោសិកាមេរសាត់មកជាប់គ្នា រួចរលាយចូលគ្នាអស់ទៅ ។ អម្បាញ់មិញនេះ រុក្ខជាតិបានរួមដំណេកសើមៗ ។ " ការរួមដំណេក " នៃរុក្ខជាតិកន្លងទៅ ។ កោសិកាឈ្មោល នឹងមេរួមគ្នាកើតបានជា " ពង " មួយ (œuf) ។ " ពង " ធំឡើង បុប្ផាណ្ឌក្លាយខ្លួនទៅជាគ្រាប់ដែរ ។

សារុបទៅ " ផ្កាកន្លងទៅ " ។ ផ្កាក្លាយខ្លួនទៅជាផ្លែ ១ មានគ្រាប់, លទ្ធផលនៃការរួមរបស់លំអងនឹងបុប្ផាណ្ឌ ។ គ្រាប់ត្រូវដីមានដី នឹងទឹកសើមៗ ក៏ដុះឡើងបានជាដើមរុក្ខជាតិមួយតូច ។ ហេតុនេះតើមនុស្សសត្វមានសភាពខុសគ្នា នឹងរុក្ខជាតិ ឬទេ ក្នុងការបង្កើតកូន - ចៅ ?

ម៉ម ណៃ

សាស្ត្រាចារ្យវិទ្យាសាស្ត្រធម្មជាតិ

វិទ្យាល័យកំពង់ធំ

# អំពីសព្ទខ្មែរ

បូញ៉ា

ចាប់តាំងពីលេខនេះទៅ ទស្សនាវដ្ដីសាស្ត្រាចារ្យនឹងបើកទំព័រថ្មីទៀត ក្រោមចំណងជើង "ទំព័រស្រាវជ្រាវ" ដើម្បីនឹងឆ្លើយតបនឹងសំណូមពររបស់មិត្តយើងខ្លះ ៗ

មានមិត្តម្នាក់បានស្រាវជ្រាវសព្ទខ្មែរទាំងឡាយ ដែលកើតឡើងអំពីចំណែកផ្សេង ៗ នៃខ្លួនយើង ។ ការងារនេះនៅមិនទាន់ចប់នៅឡើយទេ ពីព្រោះសព្ទខ្មែរយើង ក៏ដូចជាសព្ទនៃភាសាឯទៀត ៗ ដែរ សំបូរខ្លាំងណាស់ ។

ដូចនេះ សូមមិត្តណាដែលមានបំណងស្របនឹងមិត្តខាងលើនេះ ជួយធ្វើសហប្រតិបត្តិការដោយរកសព្ទផ្សេង ៗ ទៀតមកបន្ថែមព្រមទាំងពន្យល់ន័យផង ដើម្បីជាវិភាគទានដល់វប្បធម៌របស់យើង ។ សព្ទរបស់មិត្តទោះតិចក្ដី ច្រើនក្ដី បើក្រុមនិពន្ធពិនិត្យឃើញថាសមរម្យ នឹងបានចុះផ្សាយក្នុងទស្សនាវដ្ដីលេខក្រោយ ក្រោមឈ្មោះរបស់មិត្ត ។

| ខ្លួន | ត្រចៀក | ក្បាល |
|---|---|---|
| លាងខ្លួន | ត្រចៀកពាង | ក្បាលរឹង |
| ដោះខ្លួន | ត្រចៀកប៉ោត | ក្បាលខូច |
| រឹងខ្លួន | ក្រហមស្លឹកត្រចៀក | ក្បាលពីរ |
| អៀនខ្លួន | មិនដឹងជាត្រចៀកអីទេ | ក្បាលសកពង |
| ភ្នែក | ក្ងេបត្រចៀក | ហ៊ |
| ភ្នែកមុត | | ជាន់កដកក្បាល |
| ភ្នែកស្អុយ | | គឹងសរសៃក |
| ភ្នែកបុស្សី | | ផ្ទៃមាត់ផ្ទុក |
| | | រួយមាត់រួយក |

## មុខ

មុខក្រាស

មុខស្ដឹក

មុខរឹង

មុខខ្មាញ់

មុខខ្មាញ់ “ រងើម ”

មុខឆាប់

មុខពព្រើម

មុខជាមិនកើតទេ

មានមុខមានមាត់

ស្ដឹកមុខ

រីកមុខ

ធោរមុខ

បេញមុខ

បាត់មុខ ( បាត់មាត់ )

ល្វីងមុខ

វែកមុខមិនរួច

ក្រហមមុខ

សមមុខ

មិនដឹងជាយកមុខទៅទុកឯណា

អ្នកមុខ អ្នកការ

យកមុខ យកមាត់

មើលមុខគ្នាមិនត្រង់

យល់មុខ

រើសមុខ

## មាត់

មាត់រអិល

មាត់ជាទេវតា ( ចិត្តជាទេវទត្ត )

មាត់រលាញ

មាត់ក

មាត់រឹង

មាត់មនុស្ស ក្អែក ១ ជាក្អែកដប់

មាត់វែង មាត់ខ្លី

មាត់ធំ មាត់តូច

បានមាត់

បួញមាត់

ត្រូវមាត់

បាត់មាត់, បាត់មុខ

បាត់មាត់!

កុំមាត់

តមាត់

ផុតមាត់

| | |
|---|---|
| របូតមាត់ | ចុងមាត់ចុងក |
| ស្ទួរមាត់ស្ទួរក | ផ្ទៃមាត់ |
| បាត់មាត់បាត់ក | បំហាមាត់ |
| បានមាត់ | រិចមាត់ |
| បំបាត់មាត់ | ទឹកមាត់សាប |
| ថាផ្លូវហើយវែង មាត់វែងជាងផ្លូវទៅទៀត | សាបដូចទឹកមាត់ |
| បានតែមាត់ទេ | មួយម៉ាត់មួយក |
| | ដៃ |
| រហ័សតែមាត់ ត្រកៀកស្លាប់ស្លុក | ដៃត្រង់ |
| ដិតមាត់ដង្កាប់ | ដៃធំ (ទូលាយ) |
| ពុតាមមាត់ចាប មាត់ព្រាប | ដៃស្អិត |
| " ផ្ទះ ខ្ញុំ " មាត់ច្រើនណាស់ | ដៃដល់ |
| រកស៊ីមិនគ្រប់មាត់ទេ | ដៃឫស្សី |
| រកស៊ីមិនទាន់មាត់ទេ | ដៃក្លើងជើងមាន់ |
| ទឹកមាត់ប្រៃ | ដៃហោះ (ដៃឆើត) |
| ថ្វីមាត់ | បានដៃ |
| មូលមាត់ | ឲ្យតែរួចពីដៃ ( ឲ្យតែផុតពីដៃ ) |
| ស្រលៀងមាត់ ក្របួចមាត់ ខាំមាត់ | របូតដៃ ( ទប់មិនបាន ) |
| បបូរមាត់ស្ដែស | មិនរួចពីដៃខ្ញុំទេ |
| ផ្អែមមាត់ | តដៃ |

( អានតែអណ្ដាតអត់ធ្មឹងបេះតែគ្រលាស់ )

ដៃដែក

បាតដៃជាខ្នងដៃ

ឲ្យដៃ

បើកដៃ

មានដៃ

បណ្ដោយដៃ

ជាប់ដៃ

រពិសដៃ

ចូលដៃ

ហុចដៃ

ទឹកដៃ

ស្មាដៃ

បត់ជុំដៃ ( បួញមាត់ )

មួយដៃមួយជើង

ថ្វីដៃ

ជើង

ជើងវែង ៗ

ជើងថ្ទឹក

ជើងកប

ជើងមិនជាប់ដី

ដោះដៃ

ត្រូវជើង

សមជើង

ទ្រាប់ជើង

លើកជើង

យកជើង

ដេញជើង

កាច់ជើង

មួយជើង

ភាមជើង

ជាន់កែង ( ដេញតាមកុំ– )

រកជើងមិនបានគ្រប់

ប្រមុះ

មិនប្រមុះ

គ្មានប្រមុះ

ប្រមុះមិនចុះចំបើង

ពោះ

លាក់ពោះលាក់ពង

បែកពោះដួបដួក



# វត្ថុបទ & ឯកសារ

អត្ថបទអនុពាក្យ

## កោះសន្តិភាព

នៅក្នុងសាគរអាស៊ីប៉ែកអគ្នេយ៍នេះ លើកលែងតែកោះខ្លះដែលបានប្រកាន់យកមាគ៌ាអព្យភាពជាដាច់ខាតចេញ គេមិនឃើញមានកោះដទៃទៀត ដែលមានម្លប់ត្រជាក់ត្រជុំសោះឡើយ ពុំនោះសោតទេ គឺមានតែកោះមួយប៉ុណ្ណោះ កោះសុវណ្ណភូមិ ។

បរិយាកាសសុខសាន្ត ដែលឋិតនៅលើកោះនេះ មិនមែនបានមកដោយសារទេវតាជួយឡើយ តែគឺពិតជាជោគជ័យនៃការតស៊ូរបស់ប្រជាជនកោះនេះ ដែលរួមគ្នាជុំវិញព្រះអគ្គមគ្គុទ្ទេសក៍របស់ខ្លួន ។ ប្រវត្តិនៃការតស៊ូនៅលើកោះនេះ ពោរពេញទៅដោយភស្តុតាងនៃវីរភាពដ៏អង់អាច ហើយនៅតែមានដំណើរបន្តបន្ទាប់គ្នា រហូតមកទល់នឹងបច្ចុប្បន្នកាលនេះ ។ បានជាការប្តេជ្ញាប្រយុទ្ធដ៏ក្លៀវក្លានេះមានដំណើរយូរអង្វែងហើយមោះមុតដូចនេះ ពីព្រោះនៅលើកោះជិតខាង មានសត្វឥន្ទ្រីជាច្រើនដែលលុះនៅក្នុងមនោគមវិជ្ជាផ្សេងពីកោះកម្ពុជា ចេះតែខិតខំប្រើឧបាយកលយាយីអ្នកស្រុកកោះនេះដែលមិនព្រមចុះញ៉ម ហើយដើរតាមផ្លូវដែលពួកវាបានគ្រោងមកហើយ ។ អ្នកស្រុកកោះសន្តិភាព ដែលមានប្រពៃណីស្នេហាមាតុភូមិយ៉ាងជ្រាលជ្រៅជាដរាបរៀងមក មានសម្បជញ្ញៈជានិច្ច ហើយមានទស្សនៈភ្លឺស្វាងក្រៃលែង ។ គេឃើញយ៉ាងប្រត្យក្សថា ផ្លូវដែលអស់សត្វឥន្ទ្រីបានដាក់បង្ខំឲ្យអ្នកស្រុកខ្លួនដើរតាមនោះ មិនមែនជាផ្លូវស្របតាមផលប្រយោជន៍នៃកោះខ្លួនសោះឡើយ ។ ផ្លូវនោះប្រាកដជាផ្លូវដែលដឹកនាំមហាជន

**មិត្តអ្នកអាន !**

១៥

ដោយយើងមានការខកខានក្នុងត្រីមាសទី៣នៃឆ្នាំ១៩៦៣នេះ យើងសូមចេញលេខនេះជាលេខ "ឌូប" ។ ក្នុងលេខនេះ អស់មិត្តគង់នឹងបានឃើញថា យើងខំយកចិត្តទុកដាក់លំអទស្សនាវដ្ដីយើងឲ្យបានកាន់តែប្រសើរជាងមុន ៗ ឡើងទៀត ទាំងខាងអត្ថន័យ ទាំងខាងអត្ថរូប ហើយថែមទាំងបានបន្ថែម «ផ្នែក (rubrique) មួយថ្មីទៀតផង គឺ "ការស្រាវជ្រាវ" ។

ក្នុងលេខនេះ តើមិត្តពេញចិត្តនឹង «ផ្នែក» អ្វីជាងគេ? ..

ក្នុងផ្នែក "ចិត្តគរុកោសល្យ" មិត្តចង់ឲ្យយើងនិយាយពីបញ្ហាអ្វីទៀត?

ចុះក្នុងផ្នែក «អត្ថបទនិងឯកសារ» ប្រវត្តិសាស្ត្រ សេដ្ឋកិច្ច ...?

តើមិត្តមានយោបល់អ្វីស្នើទេ អំពីបការូប (le style) ហើយនិងអំពីវិធីរបៀបបង្ហាញ(présentation) របស់យើង?

ទស្សនាវដ្ដី សាស្ត្រាចារ្យ

ឲ្យទៅជួបនឹង ភយន្តរាយ បំបាំងពាំងដល ព្រាត់ប្រាស នឹងលំបាកគោកយ៉ាកតែប៉ុណ្ណោះ ។

ព្រោះហេតុហ្នឹងហើយ បានជាប្រជាករកោះទាំងនោះ កំពុងក្រោកឡើងធ្វើសេរីការរំដោះកោះខ្លួនជារៀងរាល់ថ្ងៃ ។ ការតស៊ូរបស់ប្រជាជនទាំងនេះលំបាកវេទនាខ្លាំងណាស់ ពីព្រោះសត្វតន្ត្រីសមុទ្រតែពឹងផ្អែកទៅលើមហាព្រាយមួយយ៉ាងធំសំបើម ដែលអាស្រ័យនៅលើដើមពោធិ៍ទិសបស្ចិម ។

នៅកណ្ដាលសាគរដ៏រំដេបរំជួលនេះ អ្នកស្រុកកោះសន្តិភាពប្រកាន់ស្មារតីរឹងប៉ឹងជានិច្ច ដើម្បីនឹងស្ថាបនាសេដ្ឋកិច្ចហើយនឹងការពារបូរណភាពនៃកោះខ្លួន ចំពោះល្បិចរហស្សប្រាយគ្រប់បែប យ៉ាង ដែលពួកសត្វតន្ត្រីនឹងបិសាចជាម្ចាស់វាចង្កឡើង ។ ចំណែកឯជោគជ័យដ៏រុងរឿងប្រាកដជានឹងមានដល់អ្នកកោះជាប្រាកដ!

# សេចក្ដីចំរើននៃវិទ្យាសាស្ត្រ

នៅសម័យបុព្វកាល មនុស្សយើងបានរស់នៅដោយផ្អែកលើកម្លាំងផ្ទាល់របស់ខ្លួនយ៉ាងសុទ្ធសាធ ក្នុងការប្រយុទ្ធនឹងធម្មជាតិ ។ កម្លាំងរបស់មនុស្ស បើប្រៀបធៀបនឹងកម្លាំងរបស់ធម្មជាតិ មានសភាពទន់ខ្សោយឥតឧបមា ដែលជាហេតុនាំឲ្យការប្រយុទ្ធរបស់ខ្លួន រមែងតែបរាជ័យជាញឹកញាប់ ។ ឯធម្មជាតិវិញក៏រមែងតែមានជោគជ័យសឹងតែរាល់ពេលដែរ ហើយពង្វក់បង្វិលមនុស្សយ៉ាងយង់ឃ្នង ។ សភាពការណ៍នេះ ញ៉ាំងមនុស្សមួយភាគធំឲ្យចុះញ៉មធម្មជាតិ ដោយឥតលក្ខខណ្ឌ ហើយលែងជឿលើកម្លាំងខ្លួនក៏បែរជាទៅបន់ស្រន់ពឹងផ្អែកលើកម្លាំងអច្ឆរិយអ្វីមួយ ដែលគេយល់ថាជាម្ចាស់ធម្មជាតិហើយមានឥទ្ធិពលស័ក្តិសិទ្ធិដើម្បីបង្ក្រាបវិហេសារបស់ធម្មជាតិបាន ទៅវិញ ។

ប៉ុន្តែក្នុងការតស៊ូរបស់ខ្លួន តទល់នឹងធម្មជាតិ ពីសតវត្សមួយទៅសតវត្សមួយ ពីយុគមួយទៅយុគមួយ មនុស្សប្រមូលបានការពិសោធន៍កាន់តែច្រើនឡើងៗ ហើយបានយល់អាថ៌កំបាំងរបស់ធម្មជាតិក៏កាន់តែជ្រៅទៅៗដែរ ។ ជនខ្លះដែលមានប្រាជ្ញាវាងវៃជាងគេ ហើយមានឧត្តមគតិសង្គ្រោះមនុស្សជាតិទាំងមូលដោយរំដោះមនុស្សឲ្យផុតពីការបោកបែនរបស់ធម្មជាតិ បានធ្វើពលិកម្មដ៏ឧត្តុង្គឧត្តមបំផុត រហូតដល់ ជីវិតផងក៏មានដើម្បីនឹងត្រិះរិះស្រាវជ្រាវនូវការសំងាត់ទាំងឡាយរបស់ធម្មជាតិ ដើម្បីនឹងយកមកបងក្រងជាធម៌ភាព ។ ក៏ឯលទ្ធផលនៃការស្រាវជ្រាវនេះវិញ ក្នុងបច្ចុប្បន្ននេះក៏បានចេញមកជាទ្រឹស្ដី ជាធម៌ភាពផ្សេងៗ ដែលការអនុវត្តន៍បានហូរហៀរចូលមកបំរើជីវភាពមនុស្សយើង បានយ៉ាងច្រើន នាំសុខុមាលភាពមកជូនមនុស្សយើងបាន កាន់តែធំឡើង ៗ ហើយក៏ធ្វើឲ្យមនុស្សមានប្រៀបលើធម្មជាតិ កាន់តែខ្លាំងឡើងដែរ ។

សព្វថ្ងៃនេះ មនុស្សបានមានជ័យជំនះលើធម្មជាតិមួយកំរិតហើយ ហើយកំពុងតែប្រណាំងប្រជែងគ្នា ធ្វើការរុករកក្នុងចក្រវាឡទៀត ប្រកបដោយជោគជ័យ ។ អនាគតនឹងប្រាប់យើងថា នៅមិនយូរប៉ុន្មានទៀតទេ មនុស្សលោកនឹងបានទៅជាម្ចាស់ដ៏ពិតប្រាកដនៃធម្មជាតិ កុំឲ្យតែមានសង្គ្រាមផ្ទុះឡើងជាថ្មីទៀត ។

# អង្គការសហប្រជាជាតិ

បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានផ្ទុះឡើងហើយ ជាហេតុដែលធ្វើឲ្យ «ក្រុមហ៊ុននៃប្រជាជាតិ» ត្រូវរលាយទៅ មានរដ្ឋចំនួនហាសិបមួយបានមូលមតិគ្នាជាឯកច្ឆន្ទបង្កើតអង្គការមួយឡើង ឈ្មោះ «អង្គការសហប្រជាជាតិ» ។ ធម្មនុញ្ញនៃអង្គការនេះ បានត្រូវអ្នកដំណាងនៃរដ្ឋាភិបាលទាំងឡាយនៃសហប្រជាជាតិធ្វើសច្ចាប័ន នៅក្នុងសន្និសីទសានហ្វ្រាន់ស៊ីស្កូ កាលពីថ្ងៃទីម្ភៃប្រាំមួយមិថុនាមួយប្រាំមួយរយសែសិបប្រាំ ។

ក្នុងការបង្កើតអង្គការនេះឡើង រដ្ឋជាសមាជិកទាំងឡាយបានប្រកាសយ៉ាងឧឡារិកថា «នឹងប្រតិបត្តិការអត់ឱនគ្នា» ជានឹង «រស់នៅក្នុងសន្តិភាពជាមួយគ្នា ដោយគំនិតជាអ្នកជិតខាងគ្នាល្អ» ហើយជានឹង «រួបរួមកម្លាំងគ្នាដើម្បីរក្សាទុកនូវសន្តិភាព នឹងសន្តិសុខអន្តរជាតិ» ។ សហប្រជាជាតិមានវត្ថុបំណងនឹង «រក្សាទុកនូវសន្តិភាព ហើយនឹង សន្តិសុខអន្តរជាតិ» ។ ដើម្បីនឹងសំរេចនូវបំណងនេះ អង្គការនឹងប្រតិបត្តិនូវវិធានការរួបរួមគ្នាដ៏សក្តិសិទ្ធិ ការពារហើយបញ្ចៀសមិនឲ្យមានការគំរាមកំហែងមកលើសន្តិភាព ព្រមទាំងបង្ក្រាបអំពើពតត្បាតទាំងអស់ ឬ អំពើអ្វីៗដទៃទៀត ដែលធ្វើឲ្យសន្តិភាពប្រេះឆា ។ ចំពោះបញ្ហាអន្តរជាតិទាំងឡាយ អង្គការនឹងលើកយកបញ្ហាទាំងនោះមកពិភាក្សាដោះស្រាយ «តាមមធ្យោបាយសន្តិវិធី ដោយអនុលោមទៅតាមគោលការណ៍នៃយុត្តិធម៌ នឹងច្បាប់អន្តរជាតិ» ។ ម្យ៉ាងទៀត អង្គការមានវត្ថុបំណងនឹង «ពង្រីករវាងប្រជាជាតិនានានូវការប្រស្រ័យទាក់ទងគ្នាជាមិត្តភាព ដោយផ្អែកលើការគោរពគោលការណ៍សមភាពនៃសិទ្ធិប្រជាជនហើយនឹងសិទ្ធិចាត់ចែងកិច្ចការស្រុកទេសខ្លួនដោយខ្លួនឯង ព្រមទាំងចាត់វិធានការដ៏សមរម្យដទៃទៀត ដើម្បីពង្រឹងសន្តិភាពក្នុងលោក» ។

នៅបច្ចុប្បន្នកាលនេះ អង្គការសហប្រជាជាតិបានបិតនៅចំពោះមុខបញ្ហាសំខាន់ៗជាច្រើនដែលត្រូវដោះស្រាយឲ្យស្របទៅតាមបំណងដើមរបស់ខ្លួន មានដូចជាបញ្ហាបំផ្លាញចោលនូវអាវុធបរមាណូជាដើម ។

# លទ្ធផលបណ្ដោះអាសន្ននៃការជំរឿន កាលពីថ្ងៃ ១៧ មេសា ឆ្នាំ ១៩៦៣

( ចំនួនខាងក្រោមនេះគិតជាពាន់ )

**ក្រុង**

| | |
|---|---|
| ភ្នំពេញ | 403,5 |
| ក្រុងព្រះសីហនុ | 6,6 |
| កែប | 7,8 |
| បូកគោ | 0,5 |

**ខេត្ត**

| | |
|---|---|
| កំពង់ចាម | 820 |
| កណ្ដាល | 706 |
| បាត់ដំបង | 552 |
| ព្រៃវែង | 492 |
| តាកែវ | 467 |
| កំពត | 338 |
| កំពង់ធំ | 322 |
| សៀមរាប | 313 |
| កំពង់ស្ពឺ | 307 |
| ស្វាយរៀង | 287 |
| កំពង់ឆ្នាំង | 273 |
| ពោធសាត់ | 180 |
| ក្រចេះ | 136 |
| រតនគិរី | 49,4 |
| កោះកុង | 38.7 |
| ស្ទឹងត្រែង | 34.5 |
| មណ្ឌលគិរី | 14,3 |

បើគិតមកដល់ខែ មិថុនា ១៩៦៣ មានដល់ប្រជាជនទាំងអស់: 5.750.000

ប្រុស: 2.888.000

ស្រី : 2 862.00

ស្រង់ចេញពី " កុល្យភាពដែលបង្ហាញជូនសមាជជាតិ ទី ១៥ " ទំព័រ ២៣ ។

★

## Budget consacré à l'enseignement

1955 : 294.000.000 riels soit 12 % du budget national
1961 : 776 000 000 — soit 15 % du budget national
1963 : 1 064.000.000 — soit 19 % du budget national

### Enseignement primaire

1955 : 2 491 écoles
1963 : 3.634 écoles

### Enseignement secondaires

1955 : 8 collèges et lycées
1962 : 59 collèges et lycées
1963 : 72 collèges et lycées

### Enseignement technique

1955 : 16 classes
1963 : 46 classes

### Enseignement supérieur

1955 : 278 étudiants
1963 : 2.392 étudiants

| នៅប្រទេស | អាហារូបករណ៍នៃរដ្ឋាភិបាលបរទេស | អាហារូបករណ៍នៃមន្ទីរខេមរនិស្សិត | មិនមែនជាអាហារូបករណ៍ | វិច្ឆិកា ១៩៦២ | មេសា ១៩៦៣ |
|---|---|---|---|---|---|
| សហព័ន្ធអាល្លឺម៉ង់ | ១៣ | " | " | ១ | ១៣ |
| សាធារណរដ្ឋអារ៉ាប់រួម | " | " | " | " | " |
| អូស្ត្រាលី | ១១ | " | ៤ | ១៤ | ១៥ |
| បែលហ្ស៊ិក | ១ | ១០ | " | ១០ | ១១ |
| ប៊ុលហ្គារី | ៣ | " | " | " | ៣ |
| កាណាដា | ១៩ | " | " | ១៩ | ១៩ |
| ចិន | " | " | " | " | " |
| សហរដ្ឋអាមេរិក | ១៨៥ | " | ៧ | ១៩១ | ១៩២ |
| ហ្វកម៉ូស | " | " | ១១ | ១ | ១១ |
| បារាំង | ២២ | ៥៣ | ១២៦ | ១៦៦ | ២០១ |
| អង់គ្លេស | ៦ | " | ៤២ | ២៧ | ៤៨ |
| ហាវ៉ៃ | ៤ | " | " | ៤ | ៤ |
| ហុងកុង | " | " | ១៣ | ១៤ | ១៣ |
| ជប៉ុន | ១២ | " | ៣ | ១៤ | ១៥ |
| ស្វីស | " | ៥ | ៤ | ៨ | ៩ |
| វៀតណាមខាងត្បូង | " | " | ៤៦ | ៤៤ | ៤៦ |
| ឆេកូស្លូវ៉ាគី | ១៣ | " | " | ១៣ | ១៣ |
| សហភាពសូវៀត | ៥២ | " | " | ៥០ | ៥២ |
| យូហ្គោស្លាវី | ២ | " | " | ២ | ២ |
| ភូមា | " | " | ១ | ១ | ១ |
| សារុបទាំងអស់ | ៣៤៣ | ៦៨ | ២៥៧ | ៥៨៤ | ៦៦៨ |

ស្រង់ចេញពី « គុណភាពដែលបានបង្ហាញជូនសមាជជាតិ ទី ១៥ » ទំព័រ ១១២ ។

# LA JOURNEE D'UNE PETITE JAPONAISE NOBUE A L'ECOLE

## PEDAGOGIE

De tous les petits enfants qui vont à l'école, ceux qui ont le plus de mérite sont sans aucun doute les Japonais. En lisant ces pages, vous saurez pourquoi.

L'école est la plus jolie maison du village d'Inamura-ga-Saki près de Tokio, et Nobué, la plus jolie petite fille de l'école. Assise bien droite derrière sa table, un pinceau en poils de blaireau dans la main, elle trace avec d'infinies précautions des caractères japonais sur une feuille de papier blanc. Sur sa table se trouve un godet rempli de laque allongée d'eau, dans lequel elle plonge délicatement son pinceau qu'elle égoutte ensuite, comme le maître le lui a montré. Nobué tient la tête un peu inclinée pour faire ce travail, et le soleil qui traverse les minces fenêtres de papier vient frapper l'une de ses joues brillantes et lisses, ainsi que ses mèches noires, si luisantes qu'on les dirait laquées.

Jetons un coup d'oeil à la ronde. Que remarque-t-on ? Qu'il y a autant de garçonnets que de fillettes dans la classe. L'enseignement est devenu, en effet, rigoureusement mixte au Japon, dans les classes secondaires comme dans les classes primaires. C'est là une victoire féminine très réelle. Avant, filles et garçons fréquentaient des écoles séparées, mais le niveau pédagogique des écoles de filles était très inférieur à celui des écoles de garçons. Rien de tel depuis la réforme.

### La leçon de calligraphie

La main habile de Nobué se hâte verticalement sur la feuille blanche. Chacun sait, en effet, que les Japonais écrivent et lisent, soit en colonne, de haut en bas, soit comme nous de gauche à droite. Au bout de quelques minutes, la page se trouve entièrement décorée de graphismes gracieusement retroussés, que le premier Européen venu serait bien en peine de déchiffrer, mais qui, pour Nobué et ses petits camarades, ont une signification parfaitement claire et précise. En fait, il s'agit d'une maxime d'ordre moral, propre à frapper de jeunes cerveaux. Le maître l'a inscrite au tableau. La copier le plus soigneusement possible fait l'objet du cours de calligraphie de ce matin.

Pendant longtemps, la calligraphie occupa une place très importante dans l'enseignement japonais. L'élève y consacrait un minimum de trois ou quatre heures de classe par semaine. Savoir dessiner de jolis caractères, fermes, nets et gracieux faisait partie du bagage d'une jeune fille au même titre que connaître les secrets de l'arrangement floral, ou les rites de la cérémonie du thé.

Malheureusement, cela prenait beaucoup de temps. Aussi la Loi fondamentale de 1945, qui modifia profondément et modernisa l'éducation nippone, a-t-elle rendu facultative la calligraphie dans l'enseignement primaire. Et, si Nobué ce matin s'adonne à cet art élégant, c'est que le directeur de son école a réussi à en placer deux heures par mois au programme de quatrième année.

Car Nobué est en quatrième année. Comme elle a neuf ans, cela signifie qu'elle n'a aucun retard et que son travail marche bien. Les petits Japonais commencent, en effet, à aller en classe à partir de l'âge de six ans. Ils y restent jusqu'à l'âge de quinze ans et accomplissent ainsi six années de cours élémentaire et trois années obligatoires de cours moyen C'est le système de 6 3, comme on dit là-bas. Il faut préciser également que l'année scolaire n'a pas les mêmes limites que la nôtre.

Au Japon, en effet, les enfants rentrent en classe non pas à l'automne, mais au printemps. Il y a une certaine harmonie entre le renouveau de la nature et la reprise des activités scolaires des enfants.

## 9 ans pour savoir lire

Mais que se passe-t-il soudain dans notre école d'Inamura ga-saki ? Juste ciel, quelle clameur ! De quoi briser les fragiles vitre de papier ! Mais les vitres ont l'habitude de toutes ces voix celles de Nobué et de ses compagnons quand ils se metent à lire tout haut. Car, si les petits japonais possèdent naturellement des timbres doux et mélodieux, ceux-ci peuvent s'amplifier et atteindre un diapason tout à fait assourdissant. C'est ce qui se produit en ce moment. La leçon de lecture a succédé à celle de calligraphie. Le maître a demandé aux enfants de prendre leur livre et de l'ouvrir à la bonne page. Aussitôt, cinquante petits corps, avides de remuer, ont plongé hors des bancs pour extraire des tartables cinquante livres ravissants.

